ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
PHNOM PENH WATER SUPPLY AUTHORITY



# របាយការណ៍
# ប្រចាំត្រីមាសទី១
# ២០២១

## គោលដៅយុទ្ធសាស្ត្រចម្បង របស់ រ.ទ.ស.ភ. មានដូចខាងក្រោម៖

ពង្រីកការផ្គត់ផ្គង់ទឹកទៅតំបន់ជុំវិញរាជធានីភ្នំពេញ ដោយរក្សាអត្រា និងស្តង់ដារដូចគ្នា នៅក្នុងរាជធានីភ្នំពេញ។ វិភាគថ្លៃដើម និងកំណែទម្រង់ដំណើរការ និងបែបបទដើម្បីកាត់បន្ថយថ្លៃដើមទឹក បង្កើនប្រសិទ្ធភាពបុគ្គលិក និងបន្តកសាងសមត្ថភាពរបស់សហគ្រាស។ តាំងចិត្តខ្ពស់ ចំពោះការទទួលខុសត្រូវដល់សង្គម និងបរិស្ថាន។ ប្រៀបធៀបបែបយុទ្ធសាស្ត្រ ជាមួយបណ្តាអង្គភាពទឹកស្អាតនានា ដែលមានប្រសិទ្ធភាពបំផុតក្នុងពិភពលោក។

លេខ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

លេខទូរស័ព្ទ: ៨៥៥(0)២៣៧២៤០៤៦
លេខទូរសារ: ៨៥៥(0)២៣៤២៧៦៥៧

អ៊ីម៉ែល:
ir@ppwsa.com.kh



# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ | ត្រីមាសទី១ ឆ្នាំ២០២១ | ឆ្នាំ២០២០ | ឆ្នាំ២០១៩ |
|---|---|---|---|
| ទ្រព្យសកម្មសរុប(ពាន់រៀល) | ១.៩៧៩.២៩១.១១៧ | ១.៨៦៤.៦១៨.១៤០ | ១.៦០៤.៣៤៣.៩២២ |
| បំណុលសរុប(ពាន់រៀល) | ៩១១.១៦៥.២១២ | ៨៨២.៥៦៥.៤៨៣ | ៦៩០.៦៣៩.២៨៣ |
| មូលធនសរុប(ពាន់រៀល) | ១.០៦៨.១២៥.៩០៥ | ៩៨២.០៥២.៦៥៧ | ៩១៣.៧០៤.៦៣៩ |

| លទ្ធផលហិរញ្ញវត្ថុ | ត្រីមាសទី១ ឆ្នាំ២០២១ | ត្រីមាសទី១ ឆ្នាំ២០២០ | ត្រីមាសទី១ ឆ្នាំ២០១៩ |
|---|---|---|---|
| ចំណូលសរុប(ពាន់រៀល) | ៨៤.៣០៤.៧២៦ | ៧៥.៨១៧.៣១៦ | ៥៥.២៥៨.៩៤៧ |
| ចំណេញមុនបង់ពន្ធប្រាក់ចំណេញ(ពាន់រៀល) | ៤២.៤១៦.០៣៩ | ៣៣.១៥៦.៩១៣ | ១៧.៩០៤.២៦៥ |
| ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ(ពាន់រៀល) | ៣០.៧៧១.៦០៩ | ២៦.៦០៣.៩៤៤ | ៨.៤២៨.០៦២ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ(ពាន់រៀល) | ៣០.៧៧១.៦០៩ | ២៦.៦០៣.៩៤៤ | ៨.៤២៨.០៦២ |

| អនុបាតហិរញ្ញវត្ថុ | | ត្រីមាសទី១ ឆ្នាំ២០២១ | ឆ្នាំ២០២០ | ឆ្នាំ២០១៩ |
|---|---|---|---|---|
| អនុបាតសាធនភាព | | | | |
| អនុបាតសន្ទនីយភាព | អនុបាតចរន្ត(ចំនួនដង) | ១,៥១ | ១,០៨ | ១,១៥ |
| | អនុបាតចរន្តលឿន(ចំនួនដង) | ១,១៤ | ០,៦៨ | ០,៦២ |

| | | ត្រីមាសទី១ ឆ្នាំ២០២១ | ត្រីមាសទី១ ឆ្នាំ២០២០ | ត្រីមាសទី១ ឆ្នាំ២០១៩ |
|---|---|---|---|---|
| អនុបាតចំណេញភាព | អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម(ភាគរយ) | ១,៦០ | ១,៦៥ | ០,៥៨ |
| | អនុបាតចំណេញធៀបនឹងមូលធន(ភាគរយ) | ៣,០០ | ២,៨៧ | ០,៩៤ |
| | អនុបាតគម្លាតចំណេញដុល (ភាគរយ) | ៤១,០២ | ៤១,៥០ | ៦៩,៣៧ |
| | អនុបាតគម្លាតចំណេញភាព (ភាគរយ) | ៣៦,៥០ | ៣៥,០៩ | ១៥,២៥ |
| | ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ(រៀល) | ៣៥៣,៨១ | ៣០៥,៨៩ | ៩៦,៩០ |
| អនុបាតលទ្ធភាពសងការប្រាក់ (ចំនួនដង) | | ១១៥,៧១ | ៣៥,៥៩ | ២០,៤៣ |

# ក្រាហ្វិកអំពី
# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

## បម្រែបម្រួលតម្លៃភាគហ៊ុន (គិតជារៀល) និងទំហំជួញដូរ




## ប្រាក់ចំណេញតាមបណ្តាឆ្នាំនីមួយៗ (លានរៀល)




## ប្រាក់ចំណេញសម្រាប់ត្រីមាសទី១ ឆ្នាំ២០២១ (លានរៀល)



# សមាសភាព ក្រុមប្រឹក្សាភិបាល



**ឯកឧត្តម អ៊ុំ សុថា**
រដ្ឋលេខាធិកាក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ
បច្ចេកវិទ្យា និងនវានុវត្តន៍
**ប្រធានក្រុមប្រឹក្សាភិបាល**



**ឯកឧត្តមបណ្ឌិត ស៊ឹម ស៊ីថា**
អគ្គនាយក
រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
**សមាជិកក្រុមប្រឹក្សាភិបាល**



**ឯកឧត្តម ម៉ី វ៉ាន់**
រដ្ឋលេខាធិការ
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
**សមាជិកក្រុមប្រឹក្សាភិបាល**



**ឯកឧត្តម នួន ផារ័ត្ន**
អភិបាលរងនៃគណៈអភិបាល
រាជធានីភ្នំពេញ
**សមាជិកក្រុមប្រឹក្សាភិបាល**



**លោក ម៉ា ណូរ៉ាវីន**
តំណាងនិយោជិត
នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
**សមាជិកក្រុមប្រឹក្សាភិបាល**



**លោក ចាន់ យុនហ្វេខ**
អភិបាលមិនប្រតិបត្តិតំណាង
ភាគហ៊ុនិកឯកជន
**សមាជិកក្រុមប្រឹក្សាភិបាល**



**លោក អោម សេខ បូរ៉ា**
អភិបាលឯករាជ្យ
**សមាជិកក្រុមប្រឹក្សាភិបាល**

# សេចក្ដីថ្លែងរបស់
# ប្រធានក្រុមប្រឹក្សាភិបាល



**ឯកឧត្តម អ៊ុំ សុថា**
រដ្ឋលេខាធិកាក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ
បច្ចេកវិទ្យា និងនវានុវត្តន៍
**ប្រធានក្រុមប្រឹក្សាភិបាល**

## ក្នុងត្រីមាសទី១ ឆ្នាំ២០២១ នេះ

"ដោយទទួលបានទំនុកចិត្តពីរាជរដ្ឋាភិបាល ជាមួយនឹងការឧបត្ថម្ភ គាំទ្រពីក្រសួងអាណាព្យាបាលទាំងពីរ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ បានបំពេញកាតព្វកិច្ចដោយជោគជ័យ គ្រប់សកម្មភាពធុរកិច្ចរបស់ខ្លួន។ យើងកំពុងបន្តអភិវឌ្ឍសេវាទឹកស្អាតជារៀងរាល់ថ្ងៃ ទាំងគុណភាព ទាំងបរិមាណ ដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់របស់ប្រជាជននៃទីក្រុងភ្នំពេញនិងទីក្រុងតាខ្មៅ និងចូលរួមចំណែកក្នុងដំណើរការអភិវឌ្ឍន៍របស់ទីក្រុងទាំងពីរ។"

ក្នុងត្រីមាសនេះ រ.ទ.ស.ភ. បានទទួលចំណូលសរុប ៨៤.៣០៤.៧២៦ពាន់រៀល និងប្រាក់ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញ៤២.៤១៦.០៣៩ពាន់រៀល។

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ វិនិយោគកសាងពង្រីកដំណើរការ និងជួសជុលថែរក្សាមធ្យោបាយសម្រាប់ផលិត និងប្រព័ន្ធចែកចាយទឹកស្អាត និងអនាម័យ។ ប្រើប្រាស់នូវគ្រប់វិធានការដើម្បីបង្កើនផលិតកម្មសេវាកម្ម និងធានាគុណភាពទឹកស្អាត ឆ្លើយតបទៅនឹងតម្រូវការសម្រាប់ជីវភាពរស់នៅអាជីវកម្ម-សេវាកម្មនិងឧស្សាហកម្ម។ ធ្វើអាជីវកម្ម សេវាកម្ម និងការងារផ្សេងៗទៀត ដែលទាក់ទងនឹងវិស័យទឹកស្អាត និងអនាម័យនៅក្នុងឬក្រៅប្រទេសតាមការសម្រេចរបស់ ក្រុមប្រឹក្សា-ភិបាល និងដោយអនុលោមតាមច្បាប់។

សហប្រតិបត្តិការលើផ្នែកបច្ចេកទេសពាណិជ្ជកម្ម និងហិរញ្ញវត្ថុជាមួយដៃគូអភិវឌ្ឍន៍ក្នុង និងក្រៅប្រទេសដើម្បីពង្រីក និងអភិវឌ្ឍរ.ទ.ស.ភ. ទៅតាមគោលនយោបាយ របស់រាជរដ្ឋាភិបាល។ ជានាឲ្យបាននូវចេរភាពដំណើរការផលិតកម្មអាជីវកម្ម និងហិរញ្ញវត្ថុដោយផ្សារភ្ជាប់ជាមួយប្រយោជន៍សង្គមបង្កើនប្រសិទ្ធភាពបុគ្គលិក និងបន្តកសាងសមត្ថភាពរបស់សហគ្រាស វិភាគកត្តាថ្លៃដើម និងកំណែទម្រង់ដំណើរការ និងបែបបទដើម្បីកាត់បន្ថយថ្លៃដើមទឹក ប្រៀបធៀបបែបយុទ្ធសាស្ត្រ ជាមួយបណ្ដាអង្គភាពទឹកស្អាតនានាដែលមានប្រសិទ្ធភាពបំផុតក្នុងពិភពលោក។

# សេវាដ៏មានប្រសិទ្ធភាព

យើងនៅតែបន្តធានាការផ្គត់ផ្គង់ទឹកស្អាត២៤ម៉ោងលើ២៤ម៉ោង ជាមួយនឹងគុណភាព ដែលអាចទទួលទានបានដោយផ្ទាល់ពីក្បាលរ៉ូប៊ីណេ។ ក្នុងត្រីមាសនេះ យើងផលិតបាន៥៦.២២៧.៩៨២ម$^{៣}$។ ទន្ទឹមនេះយើងបានប្រើប៉ូលី អាលុយមីញ៉ូមក្លរាយ(PAC) ជំនួសសាច់ជូរវិញដើម្បីបង្កើនគុណភាពទឹក និងកាត់បន្ថយចំណាយលើសារធាតុគីមី។

ជាលទ្ធផលនៅក្នុងត្រីមាសនេះ រ.ទ.ស.ភ. បានដាក់បំពង់មេនាំទឹក និងបណ្តាញចែកចាយទឹកស្អាតប្រវែង៤៨.៩៩៩,០២ម៉ែត្រ និងបានតបណ្តាញទឹកស្អាតជូនអតិថិជនចំនួន៤.១៨៨បណ្តាញ ក្នុងនោះអតិថិជនចំណូល-ទាបមានចំនួន២៤៦បណ្តាញ ដែលយើងតែងយកចិត្តទុកដាក់ជាទៀងទាត់។ ចំណែកអត្រាទឹកបាត់បង់នៅក្នុងត្រីមាសនេះមានចំនួន១១,៥១% ដោយសារការរីករាលដាលនៃជំងឺកូវីត-១៩ ដែលធ្វើអោយយើងពិបាកក្នុងការចែកវិក្កយបត្រ និងការលេចធ្លាយបំពង់ដែលបណ្តាលមកពីមានការអភិវឌ្ឍ និងជួសជុលពង្រីកហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ច្រើន។

# ការអនុវត្តរបស់ក្រុមប្រឹក្សាភិបាល

នៅក្នុងត្រីមាសទី១ ឆ្នាំ២០២១ នេះ ក្រុមប្រឹក្សាភិបាលអាណត្តិទី៧ របស់ រ.ទ.ស.ភ គ្រោងបើកសម័យប្រជុំពេញអង្គលើកទី៦ អាណត្តិទី៧ នាថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង០៨:៣០ តាម Online ដោយប្រើកម្មវិធី ZOOM ដែលមានរបៀបវារៈដូចខាងក្រោម ៖

១) សំណើសុំពិនិត្យ-អនុម័តលើរបាយការណ៍ប្រចាំឆ្នាំ២០២០ និងគោលការណ៍បែងចែកប្រាក់ចំណេញ និងបែងចែកភាគលាភដល់ភាគហ៊ុនិកឆ្នាំ២០២០

ក្រុមប្រឹក្សាភិបាលបានអនុម័តៈ

១. ឯកភាពជាឯកច្ឆន្ទលើសំណើសុំបែងចែកប្រាក់ចំណេញឆ្នាំ២០២០ ដូចខាងក្រោម៖
- រង្វាន់សរសើរមន្ត្រី-និយោជិត (បីខែ) : ៧.៤១៨.៩៤១.៨៨៧,០០រៀល
- មូលនិធិបម្រើផលប្រយោជន៍សង្គម (៥%) : ២.៣២៨.៥៥៦.៣០៥,៣៣រៀល
- មូលនិធិបំរុងតាមច្បាប់ (៥%) : ៤.៤១៧.៥៩២.២៥០,០០រៀល
- មូលនិធិបំរុងដោយសេរី (៥%) : ៤.៤១៧.៥៩២.២៥០,០០រៀល

២. ឯកភាពជាឯកច្ឆន្ទលើប្រាក់ចំណេញរក្សាទុក : ៥៦.៧២៩.៦៩២.០៥៦,០០រៀល

៣. ភាគលាភសរុបដែលត្រូវបែងចែក : ២២.៧៨៦.៨៦៨.៤៤៤,០០រៀល
- ទិន្នផលភាគលាភ : ៤,១០%
- ចំនួនភាគលាភក្នុងមួយភាគហ៊ុន : ២៦២រៀល/ភាគហ៊ុន
- អនុបាតនៃការបែងចែកភាគលាភ : ២៥,៧៩%
- កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកត្រូវទទួលបានភាគលាភ: ២១ មេសា ២០២១
- កាលបរិច្ឆេទចាប់ផ្តើមទូទាត់ភាគលាភ ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ និងបញ្ចប់ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២១។

២) សំណើសុំពិនិត្យ-អនុម័តលើពិធីមហាសន្និបាតភាគហ៊ុនិកលើកទី៩

ក្រុមប្រឹក្សាភិបាល បានអនុម័ត-ឯកភាព៖

១. យកថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១ ជាថ្ងៃប្រារព្ធពិធីមហាសន្និបាតភាគហ៊ុនិកលើកទី៩

២. ដំណើរការមហាសន្និបាតភាគហ៊ុនិកលើកទី៩ រួមទាំងការបោះឆ្នោត នឹងរៀបចំតាមប្រព័ន្ធ Online

៣. មហាសន្និបាតចាប់ផ្តើមពីម៉ោង៨:០០ ដោយគ្រោងរៀបចំឱ្យមានរបៀបវារៈដូចខាងក្រោម៖
- ចុះវត្តមាន (អាចពិនិត្យការចុះឈ្មោះតាមប្រព័ន្ធ Online)
- ប្រកាសហេតុ
- គោរពទង់ជាតិ
- បទបង្ហាញស្តីពីលទ្ធផលអាជីវកម្មរបស់សហគ្រាស
- បោះឆ្នោតអនុម័តលើការបែងចែកភាគលាភជូនភាគហ៊ុនិក
- បោះឆ្នោតអនុម័តលើលាភការរបស់ក្រុមប្រឹក្សាភិបាល

• មតិបញ្ចប់ និងសេចក្តីថ្លែងអំណរគុណរបស់ប្រធានគណៈអធិបតី

៤. ប្រគល់ភារកិច្ចធ្វើបទបង្ហាញពីលទ្ធផលអាជីវកម្មរបស់សហគ្រាស ជូនលោកអគ្គនាយករង រស់ គឹមលាង

៥. ផ្ទេរសិទ្ធិជូនឯកឧត្តមអគ្គនាយក ឱ្យរៀបចំដំណើរការមហាសន្និបាតភាគហ៊ុនិកលើកទី៩។

៣) សំណើសុំពិនិត្យ-សម្រេចលើលទ្ធផលរបាយការណ៍ស្ទង់មតិមន្ត្រី-និយោជិតដែលបានទិញភាគហ៊ុន រ.ទ.ស.ភ ក្នុងដំណាក់កាលបោះផ្សាយលក់ភាគហ៊ុនជាលើកដំបូង(IPO)

ក្រុមប្រឹក្សាភិបាល បានអនុម័តៈ

១) ត្រូវដោះស្រាយទៅតាមសំណូមពររបស់មន្ត្រី-និយោជិតម្នាក់ៗ ពោលគឺមិនត្រូវយកមតិភាគច្រើនមកអនុវត្តជាទូទៅទេ។

២) ការដោះស្រាយត្រូវអនុវត្តត្រឹមកម្រិត រ.ទ.ស.ភ ដោយស្នើសុំអនុសាសន៍ណែនាំពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ក្នុងករណីចាំបាច់ អាចសុំយោបល់ពីនិយ័តករមូលបត្រកម្ពុជាដើម្បីធ្វើការបញ្ជាក់បន្ថែម។

៤) សំណើសុំពិនិត្យ-សម្រេចគម្រោងចំណាយចាក់ខ្សាច់បំពេញទីតាំងដីបឹងតាមោកទំហំ២៥ហិកតា

ក្រុមប្រឹក្សាភិបាល បានឯកភាពជាគោលការណ៍ លើការរៀបចំគម្រោងក្នុងការចាក់ដីធ្វើទំនប់ព័ទ្ធជុំវិញព្រំដី ដោយត្រូវពិចារណាទៅលើនីតិវិធីអនុវត្តកិច្ចលទ្ធកម្ម លទ្ធភាពថវិកា និងការស្នើសុំប្លង់កម្មសិទ្ធិទីតាំងដីនោះ។

៥) សំណើសុំពិនិត្យ-ផ្តល់យោបល់លើអនុសាសន៍របស់ គ.ម.ក ចំពោះការតែងតាំងលេខាធិការសហគ្រាស ០១រូបបន្ថែមទៀត ដែលមានគុណវុឌ្ឍិស្របតាមប្រកាសលេខ០១១/១៨គ.ម.ក/ប្រ.ក

ក្រុមប្រឹក្សាភិបាល បានឯកភាពជាគោលការណ៍ ឱ្យ រ.ទ.ស.ភ ជ្រើសរើសលេខាធិការសហគ្រាសបន្ថែម០១រូបទៀត។

៦) របាយការណ៍ស្តីពីលទ្ធផលការងារត្រីមាសទី១ និងផែនការត្រីមាសទី២ ឆ្នាំ២០២១

ក្រុមប្រឹក្សាភិបាល បានឯកភាពទាំងស្រុងលើរបាយការណ៍ ស្តីពីលទ្ធផលការងារត្រីមាសទី១ និងផែនការត្រីមាសទី២ ឆ្នាំ២០២១។

៧) របាយការណ៍ស្តីពីលទ្ធផលការងារសវនកម្មផ្ទៃក្នុង ត្រីមាសទី១ ឆ្នាំ២០២១

ក្រុមប្រឹក្សាភិបាល បានឯកភាពទទួលជ្រាបជារបាយការណ៍។

៨) របាយការណ៍ស្តីពីលទ្ធផលកិច្ចលទ្ធកម្មអនុវត្តក្នុងដំណាច់ឆ្នាំ២០២០ និងត្រីមាសទី១ ឆ្នាំ២០២១

ក្រុមប្រឹក្សាភិបាល បានឯកភាពលើរបាយការណ៍លទ្ធផលកិច្ចលទ្ធកម្មអនុវត្តក្នុងដំណាច់ឆ្នាំ២០២០ និងត្រីមាសទី១ ឆ្នាំ២០២១។

៩) របាយការណ៍ស្តីពីមូលនិធិបម្រើផលប្រយោជន៍សង្គម ចុងឆ្នាំ២០២០ និងត្រីមាសទី១ ឆ្នាំ២០២១

ក្រុមប្រឹក្សាភិបាល បានឯកភាពទាំងស្រុងលើរបាយការណ៍លទ្ធផលប្រើប្រាស់មូលនិធិបម្រើផលប្រយោជន៍សង្គមចុងឆ្នាំ២០២០ និងក្នុងត្រីមាសទី១ ព្រមទាំងបានឯកភាពលើសំណើចំណាយទាំង៥ ដែលបានលើកឡើង។

១០) ផ្សេងៗ។

ក) របាយការណ៍ស្តីពីលទ្ធផលចរចាលក្ខខណ្ឌនៃកិច្ចសន្យាការងារជាមួយលោកបណ្ឌិត ជា វិសុទ្ធ

ក្រុមប្រឹក្សាភិបាល បានឯកភាពមោឃភាពសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលលើកទី៥ នាសម័យប្រជុំលើកទី៥ អាណត្តិទី៧ កាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២០ ដែលបានទទួលយកបេក្ខភាពលោកបណ្ឌិត ជា វិសុទ្ធ ធ្វើជាទីប្រឹក្សាក្រុមប្រឹក្សាភិបាល រ.ទ.ស.ភ នោះទេ ដោយឈរលើហេតុផលដូចខាងក្រោមៈ

១) ការចរចាមិនមានការឯកភាពគ្នា។

២) ផ្អែកតាមលក្ខន្តិកៈរបស់ រ.ទ.ស.ភ យើងមិនមាន និងពុំធ្លាប់មានប្រអប់ទីប្រឹក្សាភិបាលនេះទេ។

៣) ក្រុមប្រឹក្សាភិបាលទើបបានឯកភាពជាគោលការណ៍ ឱ្យជ្រើសរើសលេខាធិការសហគ្រាស ០១រូបបន្ថែមទៀត ដើម្បីជួយការងារក្រុមប្រឹក្សាភិបាល ដូចមានក្នុងរបៀបវារៈទី៥ខាងលើ។

ខ) សំណើសុំពិនិត្យ និងពិភាក្សាអំពីសមាសភាពគណៈកម្មាធិការតែងតាំង និងលាភការដែលបានបង្កើតតាមរយៈសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល លេខ០០៤ ក្រ.ប្រ.ភ ស.ស.រ

ក្រុមប្រឹក្សាភិបាល បានស្នើឱ្យ រ.ទ.ស.ភ ធ្វើការសិក្សាស្រាវជ្រាវបន្ថែមដើម្បីប្រមូលព័ត៌មានឱ្យបានគ្រប់ជ្រុងជ្រោយ សម្រាប់ជាមូលដ្ឋានលើកយោបល់ជូនក្រុមប្រឹក្សាភិបាលក្នុងកិច្ចប្រជុំលើកក្រោយ ដើម្បីធ្វើវិសោធនកម្មសេចក្តីសម្រេចលេខ០០៤ ក្រ.ប្រ.ភ៉ ស.ស.រ ខាងលើ។

រ.ទ.ស.ភ មានយុទ្ធសាស្ត្រច្បាស់លាស់ក្នុងការពង្រីកបណ្តាញចែកចាយទឹក ដោយមានទំនាក់ទំនងជាមួយនឹងការពង្រីកសមត្ថភាពប្រព្រឹត្តកម្ម ហើយការពង្រីកការផ្គត់ផ្គង់ទឹកទៅតំបន់ជុំវិញរាជធានីភ្នំពេញ គឺធ្វើយ៉ាងណារក្សាអត្រា និងស្តង់ដារដូចគ្នា នៅក្នុងរាជធានីភ្នំពេញ និងតាំងចិត្តខ្ពស់ចំពោះការទទួលខុសត្រូវដល់សង្គម និងបរិស្ថាន។

## សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំសូមថ្លែងសេចក្តីដឹងគុណដ៏ជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលអាណាព្យាបាលទាំងពីរ គឺក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និយ័តករមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងភាគហ៊ុនិកទាំងអស់ ដែលបានផ្តល់ទំនុកចិត្តនិងការគាំទ្រចំពោះរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។

យើងក៏មានមោទនភាព និងសូមថ្លែងអំណរគុណចំពោះមន្ត្រី និងនិយោជិតគ្រប់ថ្នាក់របស់ រ.ទ.ស.ភ. ដែលបានខិតខំបំពេញការងារដោយស្មារតីទទួលខុសត្រូវខ្ពស់ជំរុញឲ្យបានសម្រេចនូវលទ្ធផលដ៏ល្អប្រសើរនេះ។

ថ្ងៃច័ន្ទ ៥កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១
**ប្រធានក្រុមប្រឹក្សាភិបាល**

**អ៊ឹម សុថា**

# មាតិកា

ព័ត៌មានហិរញ្ញវត្ថុសង្ខេប i
ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប ii
សមាសភាពក្រុមប្រឹក្សាភិបាល iii
សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល v

ផ្នែកទី១.-ព័ត៌មានទូទៅពាក់ព័ន្ធនឹងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ០១
ក- អត្តសញ្ញាណរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ០១
ខ- លក្ខណៈធុរកិច្ច ០១

ផ្នែកទី២.-ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ០២
ក- លទ្ធផលប្រតិបត្តិការធុរកិច្ច ០២
ខ- រចនាសម្ព័ន្ធចំណូល ០៥

ផ្នែកទី៣.-របាយការណ៍ហិរញ្ញវត្ថុដែលបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ ០៦

ផ្នែកទី៤.-ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង ៣២
ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ៣២
ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ៣៦
គ-ការប្រែប្រួលសំខាន់ៗលើការលក់និងចំណូល ៣៧
ឃ-ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់និងថ្លៃទំនិញ ៣៧
ង- ផលប៉ះពាល់នៃអតិផរណា ៣៨
ច-គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល ៣៨

ផ្នែកទី៥.-ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន ៣៨

ហត្ថលេខាអភិបាលរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ៣៩

# ផ្នែកទី១: ព័ត៌មានទូទៅរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

## ក- អត្តសញ្ញាណ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

### រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ.)

### PHNOM PENH WATER SUPPLY AUTHORITY (PPWSA)

- លេខកូដស្តង់ដារ: KH1000010004
- ទីស្នាក់ការ: អគារ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
- លេខទូរស័ព្ទ: +៨៥៥(០)២៣៦៣៥៨០៨០ / ៧២៤០៤៦
- លេខទូរសារ: +៨៥៥(០)២៣៤២៧៦៥៧
- គេហទំព័រ: www.ppwsa.com.kh អ៊ីម៉ែល: ir@ppwsa.com.kh
- លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម: Co.០៨៣៩Et/២០១២
  កាលបរិច្ឆេទ: ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២
- លេខអាជ្ញាបណ្ណអាជីវកម្ម: អនុក្រឹត្យលេខ៥២អនក្រ.បក
  កាលបរិច្ឆេទ: ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៦
- សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានលេខ: ០១២/១២គ.ម.ក/ស.ស.រ.
  កាលបរិច្ឆេទ: ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១២
- ឈ្មោះបុគ្គលតំណាងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ: **ឯកឧត្តមបណ្ឌិត ស៊ឹម ស៊ីថា**

## ខ- លក្ខណៈនៃធុរកិច្ច

- វិនិយោគ កសាង ពង្រីក ដំណើរការ និងជួសជុលថែរក្សាមធ្យោបាយសម្រាប់ផលិត និងប្រព័ន្ធចែកចាយទឹកស្អាត និងអនាម័យ
- ប្រើប្រាស់នូវគ្រប់វិធានការដើម្បីបង្កើនផលិតកម្ម សេវាកម្ម និងធានាគុណភាព ទឹកស្អាតឆ្លើយតបទៅនឹងតម្រូវការសម្រាប់ជីវភាពរស់នៅអាជីវកម្ម-សេវាកម្ម និងឧស្សាហកម្ម ធ្វើអាជីវកម្ម សេវាកម្ម និងការងារផ្សេងៗទៀតដែលទាក់ទងនឹងវិស័យទឹកស្អាត និងអនាម័យនៅក្នុង ឬក្រៅប្រទេស តាមការសម្រេចរបស់ក្រុមប្រឹក្សា-ភិបាល និងដោយអនុលោមតាមច្បាប់
- សហប្រតិបត្តិការលើផ្នែកបច្ចេកទេស ពាណិជ្ជកម្ម និងហិរញ្ញវត្ថុ ជាមួយដៃគូអភិវឌ្ឍន៍ក្នុង និងក្រៅប្រទេសដើម្បីពង្រីក និងអភិវឌ្ឍ រ.ទ.ស.ភ ទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល
- ធានាឲ្យបាននូវចិរភាពដំណើរការផលិតកម្ម អាជីវកម្ម និងហិរញ្ញវត្ថុដោយផ្សារភ្ជាប់ជាមួយផលប្រយោជន៍សង្គម។
- ពង្រីកការផ្គត់ផ្គង់ទឹកនៅតំបន់ជុំវិញរាជធានីភ្នំពេញ ដោយរក្សាអត្រា និងស្តង់ដាដូចគ្នានៅក្នុងរាជធានីភ្នំពេញ
- បង្កើនប្រសិទ្ធភាពបុគ្គលិក និងបន្តកសាងសមត្ថភាពរបស់សហគ្រាស
- វិភាគកត្តាថ្លៃដើម និងកំណែទម្រង់ដំណើរការ និងបែបបទដើម្បីកាត់បន្ថយថ្លៃដើមទឹក
- ប្រៀបធៀបបែបយុទ្ធសាស្ត្រជាមួយបណ្តាញអង្គភាពទឹកស្អាតនានាដែលមានប្រសិទ្ធភាពបំផុតក្នុងពិភពលោក
- តាំងចិត្តខ្ពស់ចំពោះការទទួលខុសត្រូវដល់សង្គម និងបរិស្ថាន។

# ផ្នែកទី ២.- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ក- លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

## ក.១- លទ្ធផលការងារប្រព្រឹត្តកម្មប្រព័ន្ធចែកចាយទឹក និងការងារកាត់បន្ថយទឹកបាត់បង់

### ក.១.១- លទ្ធផលការងារប្រព្រឹត្តកម្ម

ការប្រព្រឹត្តកម្មទឹកស្អាតនៅក្នុងត្រីមាសទី១ ឆ្នាំ២០២១នេះ មានដូចក្នុងតារាងខាងក្រោម៖

| **បរិយាយ** | **ផែនការ** (គិតជា ម៉ែត្រគូប) | **អនុវត្តជាក់ស្តែង** (គិតជា ម៉ែត្រគូប) | **អត្រា** (គិតជា %) |
|---|---|---|---|
| រោងចក្រភូមិព្រែក | ១៤.៣២៨.៤៧៦ | ១៤.០៩៧.៥៤៨ | ៩៨ |
| រោងចក្រជ្រោយចង្វារ | ១៤.៦៦៧.០០០ | ១៥.២៤៨.០៦៩ | ១០៤ |
| រោងចក្រចំការមន | ៤.៧៤៧.២៦៤ | ៤.៩០៩.៨៥១ | ១០៣ |
| រោងចក្រនិរោធ | ២១.៩៨០.៤៩១ | ២១.៨២៨.៨៦៨ | ៩៩ |
| រោងចក្រម្លេច | ៩៦.២០០ | ៨៩.៧៨៧ | ៩៣ |
| រោងចក្រត្បូងឃ្មុំ | ១៣៨.១០០ | ៥៣.៨៥៩ | ៣៩ |
| **សរុប** | **៥៥.៩៥៧.៥៣១** | **៥៦.២២៧.៩៨២** | **១០០,៤៨** |

គុណភាពទឹកតាមបណ្តារោងចក្រប្រព្រឹត្តកម្មទឹកស្អាត និងបណ្តាញចែកចាយ៖

| មុខវិភាគ | ឯកតា | WHO | រោងចក្រ ភូមិព្រែក | រោងចក្រ ជ្រោយចង្វារ | រោងចក្រ ចំការមន | រោងចក្រ និរោធ | រោងចក្រ ម្លេច | រោងចក្រ ត្បូងឃ្មុំ | បណ្តាញចែកចាយ |
|---|---|---|---|---|---|---|---|---|---|
| ភាពល្អក់ | NTU | ≤ ៥ | ០,៩៧ | ០,៤៦ | ០,២១ | ០,៤០ | ០,៦១ | ១,២១ | ០,៨៧ |
| តម្លៃប៉េហាស់ | pH | ៦,៥ - ៨,៥ | ៧,២២ | ៧,៧៩ | ៧,៤៦ | ៧,២៩ | ៧,៤១ | ៧,៦៥ | ៧,៤៩ |
| ក្លរសេរី | mg/l | ០,១ - ១ | ១,៤១ | ០,៩៥ | ០,៩៨ | ១,២៥ | ១,០៨ | ០,៥៦ | ០,២៥ |
| ក្លរសរុប | mg/l | <២ | ១,៦០ | ១,០៨ | ១,១១ | ១,៤២ | ១,២៨ | ០,៧៦ | ០,៤០ |
| មេរោគកូលីហ្វម | cfu/100ml | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| មេរោគអ៊ីកូលី | cfu/100ml | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |

### ក.១.២- លទ្ធផលការងាររៀបចំ ប្រព័ន្ធចែកចាយទឹកស្អាត

ប្រវែងបំពង់ដែលបានដាក់តាមឆ្នាំនីមួយៗ (គិតជាគីឡូម៉ែត្រ)



## ក- លទ្ធផលប្រតិបត្តិការធុរកិច្ចដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក (ត)

## ក.១- លទ្ធផលការងារប្រព្រឹត្តកម្មប្រព័ន្ធចែកចាយទឹកនិងការងារកាត់បន្ថយទឹកបាត់បង់ (ត)

### ក.១.៣- លទ្ធផលការងារកាត់បន្ថយទឹកបាត់បង់

អត្រាទឹកបាត់បង់របស់ រ.ទ.ស.ភ. សម្រាប់តំបន់រាជធានីភ្នំពេញ និងតាខ្មៅ នៅមានកម្រិតនៅត្រឹមអត្រា១១,៥១% ដូចបានបង្ហាញក្នុងក្រាហ្វិចខាងក្រោម។

ក្រាហ្វិចបង្ហាញពីអត្រាទឹកបាត់បង់ពីឆ្នាំ២០០៣ ដល់ត្រីមាសទី១ ឆ្នាំ២០២១ (គិតជាភាគរយ)




## ក.២- សកម្មភាព និងលទ្ធផលការងារអាជីវកម្ម

### ក.២.១-ការងារផ្គត់ផ្គង់ទឹកស្អាត ជូនប្រជាពលរដ្ឋមានចំណូលទាប

បណ្ដាញអតិថិជនមានចំណូលទាប ក្នុងគ្រាតាមបណ្ដាឆ្នាំនីមួយៗ




### ក.២.២-ការងារតបណ្ដាញចូលផ្ទះ និងការគ្រប់គ្រងអតិថិជន

| ប្រភេទអតិថិជន | ២០១៧ (ចំនួនបណ្ដាញ) | ២០១៨ (ចំនួនបណ្ដាញ) | ២០១៩ (ចំនួនបណ្ដាញ) | ២០២០ (ចំនួនបណ្ដាញ) | ត្រីមាសទី១ ឆ្នាំ២០២១ (ចំនួនបណ្ដាញ) | ត្រីមាសទី១ ឆ្នាំ២០២១ (ភាគរយ) |
|---|---|---|---|---|---|---|
| ជីវភាព | ២៧១.៣១៧ | ៣០១.៨៣៤ | ៣២១.២១២ | ៣៣៣.០៩៩ | ៣៣៦.៤៨១ | ៨១,៦៧៦៧% |
| អាជីវកម្ម | ៥៥.៨៩១ | ៥៨.៧៨៩ | ៦២.៣៦៦ | ៦៨.១៣៦ | ៦៨.៩៣៦ | ១៦,៧៣៣៤% |
| អង្គភាពរដ្ឋ | ៦៥៥ | ៦៦៤ | ៦៩៦ | ៧៤៤ | ៧៤៤ | ០,១៨០៦% |
| អ្នកលក់ទឹក | ០៨ | ០៧ | ០៧ | ១០ | ១០ | ០,០០២៤% |
| តំណាងចែកចាយ | ២០ | ២១ | ១៧ | ១៤ | ១៤ | ០,០០៣៤% |
| Standpipe | - | ១៤ | ១៧ | ១៧ | ១៧ | ០,០០៤១% |
| បន្ទប់ជួល | ៥.៣៩៧ | ៥.៧០៣ | ៥.៧៥២ | ៥.៧៥៩ | ៥.៧៦៥ | ១,៣៩៩៤% |
| សរុប | ៣៣៣.២៨៨ | ៣៦៧.០៣២ | ៣៩០.០៦៧ | ៤០៧.៧៧៩ | ៤១១.៩៦៧ | |

## ក- លទ្ធផលប្រតិបត្តិការធុរកិច្ចដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក (ត)

## ក.៣- ការងារគ្រប់គ្រងធនធានមនុស្ស



# ផ្នែកទី ២.- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច (ត)

## ខ- រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល | ត្រីមាសទី១ ឆ្នាំ២០២១ | | ត្រីមាសទី១ ឆ្នាំ២០២០ | | ត្រីមាសទី១ ឆ្នាំ២០១៩ | |
|---|---|---|---|---|---|---|---|
| | | បរិមាណ (ពាន់រៀល) | ភាគរយ | បរិមាណ (ពាន់រៀល) | ភាគរយ | បរិមាណ (ពាន់រៀល) | ភាគរយ |
| ១ | ចំណូលពីការលក់ | ៦៨.៧២៩.០៦៣ | ៨១,៥២% | ៦៦.៨៨៧.៨៣៨ | ៨៨,២២% | ៥១.២៥២.២១៤ | ៩២,៧៦% |
| ២ | កម្រៃពីសេវាសាងសង់ | ៦.៩៦៨.៣៤២ | ៨,២៧% | ១.៦៧៨.៤២២ | ២,២១% | ១៤៧.៣៧៧ | ០,៧% |
| ៣ | ចំណូលពីការប្តូររូបិយប័ណ្ណ-សុទ្ធ | ៥៤៣.៦២៦ | ០,៦៤% | - | - | - | - |
| ៤ | ចំណូលផ្សេងៗ | ៨.០៦៣.៦៩៥ | ៩,៥៦% | ៧.២៥១.០៥៦ | ៩,៥៦% | ៣.៨៥៤.៣៥៦ | ៦,៩៨% |
| | ចំណូលសរុប | ៨៤.៣០៤.៧២៦ | | ៧៥.៨១៧.៣១៦ | | ៥៥.២៥៨.៩៤៧ | |

# ផ្នែកទី៣:

# របាយការណ៍ហិរញ្ញវត្ថុ ដែលត្រួតពិនិត្យឡើងវិញ

## ដោយសវនករឯករាជ្យ

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

**( Co.០៨៣៩ Et/២០១២ )**

**( ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា )**

**ព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្ដោះពេល**

**សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១**

លេខបញ្ជីពាណិជ្ជកម្ម៖ Co.០៨៣៩ Et/២០១២

## រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល
## សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១

**មាតិកា** ទំព័រ


| | |
|---|---|
| សេចក្ដីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល | ១ |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល | ២-៣ |
| របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល | ៤-៥ |
| របាយការណ៍បម្រែបម្រួលមូលធនសង្ខេបចន្លោះពេល | ៦ |
| របាយការណ៍លំហូរសាច់ប្រាក់សង្ខេបចន្លោះពេល | ៧-៨ |
| កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល | ៩-២១ |
| របាយការណ៍ស្ដីពីការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល | ២២-២៣ |

*លេខបញ្ជីពាណិជ្ជកម្ម៖ Co.០៨៣៩ Et/២០១២*

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ នាថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ និងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល របាយការណ៍បម្រែបម្រួលមូលធនសង្ខេបចន្លោះពេល និងរបាយការណ៍លំហូរសាច់ប្រាក់សង្ខេបចន្លោះពេលសម្រាប់ត្រីមាស និងរយៈពេល៣ខែ ដែលបានបញ្ចប់ និងកំណត់សម្គាល់សង្ខេបលើព័ត៌មានហិរញ្ញវត្ថុចន្លោះពេលដែលពាក់ព័ន្ធ (ត្រូវបានគេស្គាល់ថាជា "ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល") បានបង្ហាញនូវភាពសមស្របគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ ដោយអនុលោមតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា លេខ ៣៤ ស្តីពី *"របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល"*។

ចុះហត្ថលេខាជំនួសក្រុមប្រឹក្សាភិបាល

**ស៊ឹម ស៊ីថា**
អគ្គនាយក

**រស់ គឹមលាង**
អគ្គនាយករងទទួលបន្ទុក
ហិរញ្ញកិច្ច និងផ្សារមូលបត្រ

**អ៊ុំ សុថា**
ប្រធានក្រុមប្រឹក្សាភិបាល

ថ្ងៃច័ន្ទ ៥កើត ខែប.សាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១

១

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល នាថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១

| | កំណត់សម្គាល់ | មិនបានធ្វើសវនកម្ម<br>៣១ មីនា ២០២១<br>គិតជាពាន់រៀល | បានធ្វើសវនកម្ម<br>៣១ ធ្នូ ២០២០<br>គិតជាពាន់រៀល |
|---|---|---|---|
| **ទ្រព្យសកម្ម** | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | |
| ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៤ | ១.៥៥៤.៤៨៩.៩៦៩ | ១.៥៧៣.៦០២.០៩៩ |
| ទ្រព្យសកម្មអរូបី | | ១៣.២៧១.៩៤៤ | ១៣.០៨៣.២០៤ |
| **ទ្រព្យសកម្មរយៈពេលវែងសរុប** | | ១.៥៦៧.៧៦១.៩១៣ | ១.៥៨៦.៦៨៥.៣០៣ |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | |
| សន្និធិ | | ៨៩.១៩០.០៩២ | ៧៨.៦១២.៨៨៨ |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗ | | ១៥៦.៣៦៣.៩៨០ | ២៥.៦៤២.២០៦ |
| ទ្រព្យសកម្មកិច្ចសន្យា | ៥ | ៤១.៦៨៨.៨៦៩ | ៤២.៩២២.៥៤៧ |
| ឥណទានផ្តល់ឱ្យបុគ្គលិក | | ៧.៩៥៦.៦៥១ | ៧.៩៥៦.៦៥១ |
| ការវិនិយោគរយៈពេលខ្លី | ៦ | ៦៨.៥៧២.៣៥០ | ៦៧.៩៣៩.៧១៤ |
| គណនីពន្ធផ្សេងៗត្រូវទទួល | | ១.៤៨៥.៦៧៦ | ៤.៦៤៣.៣២៦ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | | ៤៦.២៧១.៥៨៦ | ៥០.២១៥.៥០៥ |
| **ទ្រព្យសកម្មរយៈពេលខ្លីសរុប** | | ៤១១.៥២៩.២០៤ | ២៧៧.៩៣២.៨៣៧ |
| **ទ្រព្យសកម្មសរុប** | | ១.៩៧៩.២៩១.១១៧ | ១.៨៦៤.៦១៨.១៤០ |
| **មូលធន និងបំណុល** | | | |
| **មូលធនរបស់ភាគហ៊ុនិករបស់ រ.ទ.ស.ភ** | | | |
| ដើមទុន | ៧ | ៦១៩.៣១៥.៨៨៦ | ៥៤១.២២៧.២៨២ |
| ទុនបម្រុង | ៨ | ៤១៨.០៣៨.៤១០ | ៣៥២.៤៧៣.៥៣០ |
| ចំណេញរក្សាទុក | | ៣០.៧៧១.៦០៩ | ៨៨.៣៥១.៨៤៥ |
| **មូលធនសរុប** | | ១.០៦៨.១២៥.៩០៥ | ៩៨២.០៥២.៦៥៧ |

២

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល
## នាថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ (ត)

| | កំណត់សម្គាល់ | មិនបានធ្វើសវនកម្ម ៣១ មីនា ២០២១ គិតជាពាន់រៀល | បានធ្វើសវនកម្ម ៣១ ធ្នូ ២០២០ គិតជាពាន់រៀល |
|---|---|---|---|
| **បំណុលរយៈពេលវែង** | | | |
| ប្រាក់កម្ចី | ៩ | ៥២១.២៤៩.៦២៥ | ៥១៧.២៨៨.៤០៣ |
| ជំនួយពន្យាពីរដ្ឋាភិបាល និងជំនួយផ្សេងៗ | | ១៨.៣១៩.៦១៧ | ១៨.៨២២.០៩៣ |
| បំណុលពន្ធពន្យា | | ៦៦.៥៣២.៧៥៥ | ៦២.៥០៦.៦៥៧ |
| គណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | ១០ | ៦៦.២៣១.៨៩៥ | ៦៥.១៩៥.៨៣៦ |
| **បំណុលរយៈពេលវែងសរុប** | | ៦៧២.៣៣៣.៨៩២ | ៦៦៣.៨១២.៩៨៩ |
| **បំណុលរយៈពេលខ្លី** | | | |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និង គណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | ១០ | ១៩៩.៨១១.៤៤១ | ១៥៦.៥៩៩.៨០៥ |
| ប្រាក់កម្ចី | ៩ | ២៩.១២៤.៤៤២ | ៣០.៨៤៧.១៧៣ |
| បំណុលកិច្ចសន្យា | ៥ | ២.៥១២.៥៨៥ | ៣.៦១៦.៥៦៦ |
| បំណុលពន្ធលើប្រាក់ចំណូល | | ៧.៣៨២.៨៥២ | ២៧.៦៨៨.៩៥០ |
| **បំណុលរយៈពេលខ្លីសរុប** | | ២៣៨.៨៣១.៣២០ | ២១៨.៧៥២.៤៩៤ |
| **បំណុលសរុប** | | ៩១១.១៦៥.២១២ | ៨៨២.៥៦៥.៤៨៣ |
| **មូលធន និងបំណុលសរុប** | | ១.៩៧៩.២៩១.១១៧ | ១.៨៦៤.៦១៨.១៤០ |

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល គួរតែអានជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច សម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ព្រមទាំងកំណត់សម្គាល់ពន្យល់ដែលបានភ្ជាប់ក្នុងព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

៣

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១

| | កំណត់សម្គាល់ | មិនបានធ្វើសវនកម្ម<br>សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី<br>៣១ មីនា ២០២១<br>គិតជាពាន់រៀល | <br><br>៣១ មីនា ២០២០<br>គិតជាពាន់រៀល |
|---|---|---|---|
| **ចំណូល៖** | | | |
| ចំណូលពីការលក់ | ១១ | ៦៨.៧២៩.០៦៣ | ៦៦.៨៨៧.៨៣៨ |
| កម្រៃពីការសាងសង់ | | ៦.៩៦៨.៣៨២ | ១.៦៧៨.៤២២ |
| ចំណេញពីការប្ដូររូបិយប័ណ្ណ - សុទ្ធ | | ៥៤៣.៦២៦ | - |
| ចំណូលផ្សេងៗ | | ៨.០៦៣.៦៩៥ | ៧.២៥១.០៥៦ |
| | | ៨៤.៣០៤.៧២៦ | ៧៥.៨១៧.៣១៦ |
| **ចំណាយ៖** | | | |
| ចំណាយរំលស់ទ្រព្យសកម្មរូបី និងទ្រព្យសកម្មអរូបី | | (១២.៦២០.៩៨៥) | (១២.៦៥០.១៧៤) |
| ចំណាយថ្លៃភ្លើង | | (៨.៩៨៦.៧៩៤) | (៩.៧៣៨.៥៧២) |
| ចំណាយលើអត្ថប្រយោជន៍និយោជិក | | (១៤.៦៨៥.៩៩២) | (១៣.៩១៧.៨៧៧) |
| ចំណាយវត្ថុធាតុដើមសម្រាប់ផលិតទឹកស្អាត | | (២.៩១២.៥៨៨) | (២.២៨៧.០០៨) |
| ចំណាយវត្ថុធាតុដើមសម្រាប់តភ្ជាប់បណ្ដាញទឹកតាមគេហដ្ឋាន | | (៧៥៣.៣០៥) | (៦៦៧.៣២៩) |
| ចំណាយជួសជុល និងថែទាំ | | (១.៣៧៣.៧០១) | (២.៤២៨.២០០) |
| ចំណាយសេវាសាងសង់ | | (៦.៥០៧.៣៥០) | (១.៥៦៨.៩៩៣) |
| ឱនភាពលើឥណទានផ្ដល់ឱ្យបុគ្គលិក | | - | (៥២.១៧៥) |
| ចំណាយប្រតិបត្តិការផ្សេងៗ | | (១.៩២១.៨៥៧) | (១.៣៣៨.១៦៩) |
| ខាតពីការប្ដូររូបិយប័ណ្ណ - សុទ្ធ | | - | (២០៨.៤៤៩) |
| | | (៤៩.៧២២.៥៧២) | (៤៤.៣៥៦.៥៤៦) |
| **ចំណេញប្រតិបត្តិការ** | | **៣៤.៥៨២.១៥៤** | **៣១.៤៦០.៧៧០** |
| ចំណូលការប្រាក់ | ១២ | ៨.១៣២.៧៤២ | ២.៥១១.៤៤៨ |
| ចំណាយការប្រាក់ | ១៣ | (២៩៨.៨៥៧) | (៨១៥.៣០៥) |
| **ចំណេញមុនបង់ពន្ធ** | | **៤២.៤១៦.០៣៩** | **៣៣.១៥៦.៩១៣** |
| ពន្ធលើប្រាក់ចំណូល | ១៤ | (១១.៦៤៤.៤៣០) | (៦.៥៥២.៩៦៩) |
| **ចំណេញក្នុងគ្រា តំណាងឱ្យលទ្ធផលលម្អិតផ្សេងៗក្នុងគ្រា** | | **៣០.៧៧១.៦០៩** | **២៦.៦០៣.៩៤៤** |

## រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ (ត)

| | កំណត់សម្គាល់ | មិនបានធ្វើសវនកម្ម សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី ៣១ មីនា ២០២១ គិតជាពាន់រៀល | ៣១ មីនា ២០២០ គិតជាពាន់រៀល |
|---|---|---|---|
| ចំណេញក្នុងមួយភាគហ៊ុនរបស់ភាគហ៊ុនិក រ.ទ.ស.ភ | | | |
| ចំណេញក្នុងមួយភាគហ៊ុនគោល (គិតជាប្រាក់រៀល) | | ៣៩៣,៨១ | ៣០៥,៨៩ |
| ចំណេញក្នុងមួយភាគហ៊ុនថយចុះ (គិតជាប្រាក់រៀល) | | ៣៩៣,៨១ | ៣០៥,៨៩ |

របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល គួរតែអានជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច សម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ព្រមទាំងកំណត់សម្គាល់ពន្យល់ដែលបានភ្ជាប់ក្នុងព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍បម្រែបម្រួលមូលធនសង្ខេបចន្លោះពេល
## សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១

| | កំណត់សម្គាល់ | ដើមទុន គិតជាពាន់រៀល | ទុនបម្រុង គិតជាពាន់រៀល | ចំណេញរក្សាទុក គិតជាពាន់រៀល | មូលធនសរុប គិតជាពាន់រៀល |
|---|---|---|---|---|---|
| **មិនបានធ្វើសវនកម្ម** | | | | | |
| **សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២១** | | **៥៤១.២២៧.២៨២** | **៣៥២.៤៧៣.៥៣០** | **៨៨.៣៥១.៨៤៥** | **៩៨២.០៥២.៦៥៧** |
| ចំណេញក្នុងគ្រា តំណាងឱ្យលទ្ធផលលម្អិតផ្សេងៗក្នុងគ្រា | | - | - | ៣០.៧៧១.៦០៩ | ៣០.៧៧១.៦០៩ |
| **ប្រតិបត្តិការជាមួយម្ចាស់ក្រុមហ៊ុន** | | | | | |
| ការបន្ថែមដើមទុន | | ៧៨.០៨៨.៦០៤ | - | - | ៧៨.០៨៨.៦០៤ |
| ការផ្ទេរទៅគណនីទុនបម្រុង | | - | ៦៥.៥៦៤.៨៨០ | (៦៥.៥៦៤.៨៨០) | - |
| ភាគលាភ | ១៥ | - | - | (២២.៧៨៦.៩៦៥) | (២២.៧៨៦.៩៦៥) |
| **ប្រតិបត្តិការជាមួយម្ចាស់ក្រុមហ៊ុនសរុប** | | **៧៨.០៨៨.៦០៤** | **៦៥.៥៦៤.៨៨០** | **(៨៨.៣៥១.៨៤៥)** | **៥៥.៣០១.៦៣៩** |
| **សមតុល្យនាថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១** | | **៦១៩.៣១៥.៨៨៦** | **៤១៨.០៣៨.៤១០** | **៣០.៧៧១.៦០៩** | **១.០៦៨.១២៥.៩០៥** |
| | | | | | |
| **មិនបានធ្វើសវនកម្ម** | | | | | |
| **សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២០** | | **៥៤១.២២៧.២៨២** | **៣៣៩.១៨៥.៤៤៤** | **៣៣.២៩១.៩១៣** | **៩១៣.៧០៤.៦៣៩** |
| ចំណេញក្នុងគ្រា តំណាងឱ្យលទ្ធផលលម្អិតផ្សេងៗក្នុងគ្រា | | - | - | ២៦.៦០៣.៩៤៤ | ២៦.៦០៣.៩៤៤ |
| **សមតុល្យនាថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០** | | **៥៤១.២២៧.២៨២** | **៣៣៩.១៨៥.៤៤៤** | **៥៩.៨៩៥.៨៥៧** | **៩៤០.៣០៨.៥៨៣** |

របាយការណ៍បម្រែបម្រួលមូលធនសង្ខេបចន្លោះពេល គួរតែអានជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច សម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ព្រមទាំងកំណត់សម្គាល់ពន្យល់ដែលបានភ្ជាប់ក្នុងព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍លំហូរសាច់ប្រាក់សង្ខេបចន្លោះពេល
## សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១

| | កំណត់សម្គាល់ | មិនបានធ្វើសវនកម្ម សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី ៣១ មីនា ២០២១ គិតជាពាន់រៀល | ៣១ មីនា ២០២០ គិតជាពាន់រៀល |
|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | |
| **ចំណេញមុនបង់ពន្ធ** | | ៤២.៤១៦.០៣៩ | ៣៣.១៥៦.៩១៣ |
| និយ័តកម្មលើ៖ | | | |
| រំលស់ទ្រព្យសកម្មអរូបី | | ៤០១.៨៤៣ | ៦១៤.២៨៨ |
| រំលស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | | ១២.២១៩.១៤២ | ១២.០៣៥.៨៨៦ |
| រំលស់ជំនួយពន្យាពីរដ្ឋាភិបាល និងជំនួយផ្សេងៗ | | (៥០២.៤៧៦) | (៥៦៦.៣៩៥) |
| ការកត់ត្រាត្រឡប់នៃឱនភាពលើឥណទានផ្តល់ឱ្យបុគ្គលិក | | - | ៥២.១៧៥ |
| ការជម្រះបញ្ជី៖ | | | |
| - ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | | ២៥.០០៨ | ៤៧៨.៤៧៦ |
| ចំណូលការប្រាក់ | | (៤៦៣.៤៨៩) | (២៣២.១០៧) |
| ចំណាយការប្រាក់ | | ២៩៨.៨៥៧ | ៣៤៨.០៩៨ |
| ចំណេញសុទ្ធមិនពិតពីការប្តូររូបិយប័ណ្ណ | | (៧.៦៦៩.២៥៣) | (១.៨១២.១៣៤) |
| **ចំណេញប្រតិបត្តិការមុនបម្រែបម្រួលទុនបង្វិល** | | **៤៦.៧២៥.៦៧១** | **៤៤.០៧៥.២០០** |
| (កើនឡើង)/ថយចុះសន្និធិ | | (១០.៥៧៧.២០៤) | ៥.៦២១.០០១ |
| កើនឡើងគណនីអតិថិជនពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗ | | (២.៤៩៥.៤០២) | (២៦.៥៧១.៣៤៩) |
| កើនឡើង/(ថយចុះ)គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | | ២០.២៥០.៤០០ | (៤៧.៣០៦.៣៩៨) |
| ថយចុះ/(កើនឡើង)ទ្រព្យសកម្មកិច្ចសន្យា | | ១.២៣៣.៦៧៨ | (១០.៦០៨.៤៧២) |
| (ថយចុះ)/កើនឡើងបំណុលកិច្ចសន្យា | | (១.១០៣.៩៨១) | ២.៨៣៨.៥៤៥ |
| កើនឡើងប្រាក់កក់ថ្លៃទឹកដែលត្រូវបង្វិលសងវិញ | | ១.០៣៦.០៥៩ | ១.១០២.២៧២ |
| **សាច់ប្រាក់សុទ្ធបានពី ឬ(ប្រើប្រាស់ក្នុង)ប្រតិបត្តិការ** | | **៥៥.០៦៩.២២១** | **(៣០.៨៤៩.២០១)** |
| ពន្ធលើប្រាក់ចំណូលបានបង់ | | (២៤.៧៦៦.៧៨០) | (៥.៥៥២.៧៧២) |
| **សាច់ប្រាក់សុទ្ធបានពី ឬ(ប្រើប្រាស់ក្នុង)សកម្មភាពប្រតិបត្តិការ** | | **៣០.៣០២.៤៤១** | **(៣៦.៤០១.៩៧៣)** |

៧

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍លំហូរសាច់ប្រាក់សង្ខេបចន្លោះពេល
## សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ (ត)

| | កំណត់សម្គាល់ | មិនបានធ្វើសវនកម្ម សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី ៣១ មីនា ២០២១ គិតជាពាន់រៀល | ៣១ មីនា ២០២០ គិតជាពាន់រៀល |
|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | |
| ការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | | (៤២.៨៩៥.៧១២) | (១៦.៣១៣.៩០៦) |
| ការទិញទ្រព្យសកម្មអរូបី | | (៥៩០.៥៨៣) | (២៣០.១៦៧) |
| ទ្រព្យសកម្មផ្ទេរពីរោងចក្រផលិតទឹកស្អាតត្បូងឃ្មុំ | | (៧៨.១៩២.២៦០) | - |
| កើនឡើងការវិនិយោគរយៈពេលខ្លី | | (៦៣២.៦៣៦) | (៥.៥៨៩.៨២៩) |
| ការប្រាក់ដែលបានធ្វើមូលធនកម្មលើទ្រព្យសកម្មដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ | | (១.១៦៥.៩២៥) | (៧៦៤.៨០១) |
| ការប្រាក់បានទទួល | | ៩៥៨.៩៩៤ | ៦៦៩.៤១៧ |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | | **(១២១.១១៨.១២២)** | **(២២.២២៩.២៨៦)** |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | |
| សាច់ប្រាក់បានមកពីការបន្ថែមដើមទុន | | ៧៨.០៨៨.៦០៤ | - |
| ការបង់ភាគលាភ | | - | (៦.៨៨៤.៧៨៦) |
| សាច់ប្រាក់ទទួលបានពីកម្ចី | | ២២.៤៤៣.១៨៧ | ៥៤.០០៤.៨៧០ |
| ការប្រាក់បានបង់ | | (៧៦៥.៤៤២) | (៨៨៥.៦១៦) |
| ការបង់សងប្រាក់កម្ចី | | (១១.៨៩៤.៥៨៨) | (១០.០៣៥.១៦២) |
| **សាច់ប្រាក់សុទ្ធបានមកពីសកម្មភាពហិរញ្ញប្បទាន** | | **៨៧.៨៧១.៧៦២** | **៣៦.១៩៩.៣០៦** |
| **ថយចុះសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ** | | (៣.៩៤៣.៩១៩) | (២២.៤៣១.៩៥៣) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅដើមគ្រា** | | ៥០.២១៥.៥០៥ | ៥៥.២១២.០៧០ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅចុងគ្រា** | | ៤៦.២៧១.៥៨៦ | ៣២.៧៨០.១១៧ |

របាយការណ៍លំហូរសាច់ប្រាក់សង្ខេបចន្លោះពេល គួរតែអានជាមួយនឹង របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច សម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ព្រមទាំងកំណត់សម្គាល់ពន្យល់ដែលបានភ្ជាប់ក្នុងព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១

## ១. ព័ត៌មានអំពីក្រុមហ៊ុន

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ហៅកាត់ថា ("រ.ទ.ស.ភ") ស្ថិតក្រោមការគ្រប់គ្រងផ្នែកបច្ចេកទេសរបស់ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងស្ថិតក្រោមការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយមានការិយាល័យកណ្តាលនៅរាជធានីភ្នំពេញ។ រ.ទ.ស.ភ ត្រូវបានទទួលស្គាល់ដោយក្រសួងពាណិជ្ជកម្ម ថាជាសហគ្រាសសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច ក្រោមលេខចុះបញ្ជីពាណិជ្ជកម្ម Co. ០៨៣៩ Et/២០១២ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២។

ការិយាល័យចុះបញ្ជីរបស់ រ.ទ.ស.ភ មានទីតាំងស្ថិតនៅអគារលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

សកម្មភាពចម្បងរបស់ រ.ទ.ស.ភ គឺការផលិត និងចែកចាយទឹកស្អាតសម្រាប់ការប្រើប្រាស់ទូទៅរបស់សាធារណជននៅរាជធានីភ្នំពេញ។ គោលដៅរបស់ រ.ទ.ស.ភ គឺ៖

- វិនិយោគ កសាង ពង្រីក ដំណើរការ ជួសជុល និងថែរក្សាមធ្យោបាយសម្រាប់ផលិត និងចែកចាយទឹកស្អាត
- គ្រប់គ្រងបរិក្ខារដើម្បីបង្កើនផលិតកម្មទឹក និងបង្កើនសេវាកម្ម និងគុណភាពទឹកស្អាតដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់
- ដំណើរការអាជីវកម្ម សេវាកម្ម និងភារកិច្ចពាក់ព័ន្ធនឹងការផ្គត់ផ្គង់ទឹកស្អាត ស្របតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា
- ធ្វើសហប្រតិបត្តិការលើផ្នែកបច្ចេកវិទ្យា ពាណិជ្ជកម្ម និងហិរញ្ញវត្ថុជាមួយដៃគូអភិវឌ្ឍន៍ក្នុងស្រុក និងក្រៅប្រទេស ដើម្បីពង្រីក និងអភិវឌ្ឍ រ.ទ.ស.ភ ទៅតាមគោលនយោបាយរបស់រដ្ឋាភិបាល និង
- ធានាឱ្យបាននូវចីរភាពដំណើរការផលិតកម្ម អាជីវកម្ម និងហិរញ្ញវត្ថុ សម្រាប់ផលប្រយោជន៍សាធារណៈ

## ២. មូលដ្ឋាននៃការរៀបចំ

ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ រ.ទ.ស.ភ មិនត្រូវបានធ្វើសវនកម្មទេ ហើយត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដារគណនេយ្យអន្តរជាតិកម្ពុជា លេខ៣៤ ស្តីពី *របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល*។

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ (ត)

## ២. មូលដ្ឋាននៃការរៀបចំ (ត)

ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល មិនរួមបញ្ចូលគ្រប់កំណត់សម្គាល់ទាំងឡាយណាដែលជាទូទៅត្រូវបានរួមបញ្ចូលទៅក្នុងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំឡើយ ប៉ុន្តែ កំណត់សម្គាល់ពន្យល់មួយចំនួនត្រូវបានរួមបញ្ចូលដើម្បីពន្យល់ពីព្រឹត្តិការណ៍ និងប្រតិបត្តិការ ដែលមានសារៈសំខាន់ដល់ការយល់ដឹងពីបម្រែបម្រួលក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និងដំណើរការរបស់ រ.ទ.ស.ភ តាំងពីរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនាការិយបរិច្ឆេទមុន។ អាស្រ័យហេតុនេះ ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល គួរតែអានជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលបានធ្វើសវនកម្មរួច សម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ និងសេចក្តីប្រកាសជាសាធារណៈនានា ដែលបានធ្វើឡើងដោយរបស់ រ.ទ.ស.ភ នៅអំឡុងគ្រារាយការណ៍ចន្លោះពេល។

គោលនយោបាយគណនេយ្យដែលបានអនុវត្ត គឺមានភាពដូចគ្នាទៅនឹងការិយបរិច្ឆេទហិរញ្ញវត្ថុមុន និងគ្រារាយការណ៍ចន្លោះពេលដែលពាក់ព័ន្ធ។

## ៣. កត្តារដូវកាល ឬ វដ្ត

លើកលែងតែត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល ប្រតិបត្តិការរបស់ រ.ទ.ស.ភ មិនត្រូវបានរងផលប៉ះពាល់ជាសារវន្តដោយកត្តារដូវកាល ឬ វដ្តនោះទេ។

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល
## សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ (ត)

### ៤. ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ

| | មិនបានធ្វើសវនកម្ម<br>៣១ មីនា ២០២១<br>គិតជាពាន់រៀល | បានធ្វើសវនកម្ម<br>៣១ ធ្នូ ២០២០<br>គិតជាពាន់រៀល |
|---|---:|---:|
| **ថ្លៃដើម** | | |
| សមតុល្យដើមគ្រា/ឆ្នាំ | ២.០៧៥.៣៦៩.៣៤៥ | ១.៨២៧.៥៧៩.៤៩៨ |
| ការទិញបន្ថែម | ១២១.៨៥៣.៨៩៧ | ២៤៩.៩៣៣.០៤២ |
| ការផ្ទេរទៅទ្រព្យសកម្មអរូបី | - | (១.៥៥១.១៥៤) |
| ការផ្ទេរទៅគណនីអតិថិជនពាណិជ្ជ និងគណនីត្រូវទទួលផ្សេងៗ * | (១២៨.៧២១.៨៧៧) | - |
| ការជំរះចេញពីបញ្ជី | (២៥.០០៨) | (៥៩២.០៤១) |
| សមតុល្យចុងគ្រា/ឆ្នាំ | ២.០៦៨.៤៧៦.៣៥៧ | ២.០៧៥.៣៦៩.៣៤៥ |
| **រំលស់បង្គរ** | | |
| សមតុល្យដើមគ្រា/ឆ្នាំ | ៥០១.៧៦៧.២៤៦ | ៤៥៣.៥៤៧.៩៤៤ |
| រំលស់ក្នុងគ្រា/ឆ្នាំ | ១២.២១៩.១៤២ | ៤៨.២១៩.៣០២ |
| សមតុល្យចុងគ្រា/ឆ្នាំ | ៥១៣.៩៨៦.៣៨៨ | ៥០១.៧៦៧.២៤៦ |
| **តម្លៃយោង** | | |
| សមតុល្យចុងគ្រា/ឆ្នាំ | ១.៥៥៤.៤៨៩.៩៦៩ | ១.៥៧៣.៦០២.០៩៩ |

* ទាំងនេះតំណាងឱ្យបុរេប្រទានឱ្យអ្នកផ្គត់ផ្គង់ ដែលទាក់ទងនឹងការសាងសង់កំពុងដំណើរការដែលបានធ្វើមូលធនកម្មនៅការិយបរិច្ឆេទមុន ដែលការគ្រប់គ្រងទៅលើទ្រព្យសម្បត្តិទាំងនោះ មិនទាន់បានប្រគល់ទៅ រ.ទ.ស.ភ នាថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ នៅឡើយទេ។ គណៈគ្រប់គ្រងរបស់ រ.ទ.ស.ភ បានកែតម្រូវដោយ កត់ត្រាត្រឡប់បុរេប្រទានឱ្យអ្នកផ្គត់ផ្គង់ទាំងនេះ ពីការសាងសង់កំពុងដំណើរការ ទៅគណនីត្រូវទទួលផ្សេងៗ សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១។

## រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល
## សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ (ត)

### ៤. ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ (ត)

ក្នុងអំឡុងត្រីមាស និងសម្រាប់រយៈពេល៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ រ.ទ.ស.ភ បានធ្វើការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារដោយទូទាត់ជាសាច់ប្រាក់ដូចខាងក្រោម៖

| | មិនបានធ្វើសវនកម្ម សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី ៣១ មីនា ២០២១ គិតជាពាន់រៀល | ៣១ មីនា ២០២០ គិតជាពាន់រៀល |
|---|---|---|
| ការទិញបន្ថែម | ១២១.៨៥៣.៨៩៧ | ១៥.២២៦.៦៦៩ |
| ទ្រព្យសកម្មផ្ទេរពីរោងចក្រផលិតទឹកស្អាតត្បូងឃ្មុំ | (៧៨.១៩២.២៦០) | - |
| កើនឡើងគណនីផ្គត់ផ្គង់ និងប្រាក់ធានាប្រតិបត្តិការ | - | ១.៨៥១.៧៣៩ |
| មូលធនកម្មលើការប្រាក់លើទ្រព្យសកម្មដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ | (១.១៦៥.៩២៥) | (៧៦៤.៨០២) |
| ការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ទូទាត់ជាសាច់ប្រាក់ | ៤២.៤៩៥.៧១២ | ១៦.៣១៣.៦០៦ |

### ៥. ទ្រព្យសកម្មកិច្ចសន្យា ឬ(បំណុលកិច្ចសន្យា)

| | មិនបានធ្វើសវនកម្ម ៣១ មីនា ២០២១ គិតជាពាន់រៀល | បានធ្វើសវនកម្ម ៣១ ធ្នូ ២០២០ គិតជាពាន់រៀល |
|---|---|---|
| **ទ្រព្យសកម្មកិច្ចសន្យា** | | |
| ទ្រព្យសកម្មកិច្ចសន្យាទាក់ទងនឹងកិច្ចសន្យាសេវាសាងសង់ | ៤.៣៧០.៩៧៤ | ៤.៨៦១.២៧០ |
| ទ្រព្យសកម្មកិច្ចសន្យាទាក់ទងនឹងការលក់ទឹកស្អាត | ៣៧.៣១៧.៨៩៥ | ៣៨.០៦១.២៧៧ |
| | ៤១.៦៨៨.៨៦៩ | ៤២.៩២២.៥៤៧ |
| **បំណុលកិច្ចសន្យា** | | |
| បំណុលកិច្ចសន្យាទាក់ទងនឹងកិច្ចសន្យាសេវាសាងសង់ | ២.៥១២.៥៨៥ | ៣.៦១៦.៥៦៦ |

## រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល
## សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ (ត)

### ៦. ការវិនិយោគរយៈពេលខ្លី

ទាំងនេះតំណាងឱ្យប្រាក់បញ្ញើមានកាលកំណត់នៅគ្រឹះស្ថានហិរញ្ញវត្ថុសម្រាប់រយៈពេលចន្លោះពី៣ ទៅ១២ខែ (២០២០៖ ៤ ទៅ ១២ខែ) ហើយទទួលបានការប្រាក់ពី ១,៥% ទៅ ៤,២៥% (២០២០៖ ១,៥% ទៅ ៤,០០%) ក្នុងមួយឆ្នាំ។

### ៧. ដើមទុន

នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបង្កើនដើមទុននៅ រ.ទ.ស.ភ។ ដោយគ្មានការបោះផ្សាយភាគហ៊ុនធម្មតារបស់ រ.ទ.ស.ភ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានណែនាំឱ្យ រ.ទ.ស.ភ បញ្ចូលទ្រព្យសកម្ម បំណុល និងមូលធនរបស់រោងចក្រផលិតទឹកស្អាតខេត្តត្បូងឃ្មុំមកក្នុងបញ្ជីរបស់ រ.ទ.ស.ភ ដែលមានទឹកប្រាក់ចំនួន ៧៨.០៨៨.៦០៤.០០០ រៀល។

### ៨. ទុនបម្រុង

| | ដើមទុនបម្រុង គិតជាពាន់រៀល | ទុនបម្រុងតាមច្បាប់ គិតជាពាន់រៀល | ទុនបម្រុងទូទៅ គិតជាពាន់រៀល | ទុនបម្រុងសម្រាប់ការអភិវឌ្ឍ គិតជាពាន់រៀល | សរុប គិតជាពាន់រៀល |
|---|---|---|---|---|---|
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២០ (បានធ្វើសវនកម្ម) | ១.៦៤៨.៤៣៥ | ២៦.០៣៥.៧៨៩ | ២៦.០៣៥.៧៨៩ | ២៨៥.៤៦៥.៤៣១ | ៣៣៩.១៨៥.៤៤៤ |
| ផ្ទេរពីចំណេញរក្សាទុក | - | ១.៦៦៤.៥៩៦ | ១.៦៦៤.៥៩៦ | ៩.៩៥៨.៨៩៤ | ១៣.២៨៨.០៨៦ |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ (បានធ្វើសវនកម្ម) | ១.៦៤៨.៤៣៥ | ២៧.៧០០.៣៨៥ | ២៧.៧០០.៣៨៥ | ២៩៥.៤២៤.៣២៥ | ៣៥២.៤៧៣.៥៣០ |
| ផ្ទេរពីចំណេញរក្សាទុក | - | ៤.៤១៧.៥៩២ | ៤.៤១៧.៥៩២ | ៥៦.៧២៩.៦៩៦ | ៦៥.៥៦៤.៨៨០ |
| នាថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ (មិនបានធ្វើសវនកម្ម) | ១.៦៤៨.៤៣៥ | ៣២.១១៧.៩៧៧ | ៣២.១១៧.៩៧៧ | ៣៥២.១៥៤.០២១ | ៤១៨.០៣៨.៤១០ |

នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១ ក្រុមប្រឹក្សាភិបាលបានអនុម័តផ្ទេរប្រាក់ចំណេញរក្សាទុកទៅគណនីទុនបម្រុង ដែលមានទឹកប្រាក់ចំនួន ៦៥.៥៦៤.៨៨០.០០០រៀល។

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ (ត)

### ៩. ប្រាក់កម្ចី

| | រូបិយប័ណ្ណ | អត្រាការប្រាក់ធម្មតា | ឆ្នាំនៃកាលវសាន្ត | តម្លៃយោង |
|---|---|---|---|---|
| **នាថ្ងៃទី១ ខែមករា ឆ្នាំ ២០២១** | | | | ៥៤៨.១៣៥.៥៧៦ |
| **បោះផ្សាយថ្មី** | | | | |
| ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង - ឥណទានលេខ ១១៧៦ | | | | |
| ០១ S | ដុល្លារអាមេរិក | ០,៩០០% | ២០៣៨ | ៥.៦៩២.៥៦០ |
| ធនាគារវិនិយោគអឺរ៉ុប ("EIB") | ដុល្លារអាមេរិក | ០,៩៦៥% | ២០៤៨ | ១៦.៨០០.៦២៧ |
| **ទូទាត់សង** | | | | |
| **ថ្លៃដើម** | | | | |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - JICA | យ៉េន | ០,៦៦០% | ២០៤៩ | (៨៦៦.៣០០) |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - ធនាគារអភិវឌ្ឍន៍អាស៊ី | SDR | ១,៦៥០% | ២០៣៧ | (១.១៨៨.៧៤១) |
| ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង - ឥណទានលេខ ១១២១ | | | | |
| ០១ F | អឺរ៉ូ | ០,២៥០% | ២០២៥ | (៩.៨៣៩.៥៤៧) |
| **ការប្រាក់** | | | | |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - JICA | យ៉េន | ០,៦៦០% | ២០៤៩ | (១៦១.៦៤៤) |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - ធនាគារអភិវឌ្ឍន៍អាស៊ី | SDR | ១,៦៥០% | ២០៣៧ | (៣២៣.៤០៥) |
| ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង - ឥណទានលេខ ១១២១ | | | | |
| ០១ F | អឺរ៉ូ | ០,២៥០% | ២០២៥ | (១១១.៣៨៤) |
| ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង - ឥណទានលេខ ១១៧៤ | | | | |
| ០១ P | ដុល្លារអាមេរិក | ១,៨០០% | ២០៣៧ | (១.៣៣៤.៩៣៤) |
| **ការប្រាក់បង្ករ** | | | | ១.៤៦៤.៧៨២ |
| **ចំណេញមិនពិតពីការប្តូររូបិយប័ណ្ណ** | | | | (៧.៨៤៣.៥២៤) |
| **នាថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១** | | | | ៥៥០.៣៧៤.០៦៧ |

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ (ត)

### ១០. គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ

| | មិនបានធ្វើសវនកម្ម ៣១ មីនា ២០២១ គិតជាពាន់រៀល | បានធ្វើសវនកម្ម ៣១ ធ្នូ ២០២០ គិតជាពាន់រៀល |
|---|---|---|
| **រយៈពេលវែង៖** | | |
| ប្រាក់កក់ថ្លៃទឹកដែលត្រូវបង្វិលសងវិញ | ៦៦.២៣១.៨៩៥ | ៦៥.១៩៥.៨៣៦ |
| **រយៈពេលខ្លី៖** | | |
| **គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម** | | |
| ភាគីទីបី | ៩៦.០០៦.០៨៩ | ៧៨.១២៣.៩៣៣ |
| **គណនីអ្នកផ្គត់ផ្គង់ផ្សេងៗ** | | |
| ប្រាក់លើកទឹកចិត្តបុគ្គលិកបង្គរ | ១០.១៩៣.៥១៤ | ៨.៧៤៣.៤២៧ |
| ទឹកប្រាក់ជំពាក់សាលារាជធានីភ្នំពេញ | ៤០.៩៣៩.៦៩៣ | ៣៨.៥២៤.៣២២ |
| ប្រាក់ធានាប្រតិបត្តិការ | ៦៧.៣១៣ | ៦៧.៣១៣ |
| ភាគលាភដែលត្រូវបង់ | ៣៩.៧៩០.៧១៩ | ១៧.០០៣.២៥៤ |
| ពន្ធត្រូវបង់ផ្សេងៗ | ៣២១.៨៩៨ | ៥៨៤.៧៥១ |
| ប្រាក់ជំពាក់បង្គរ | ៦.០៣៤.២០០ | ៧.១៩១.២៥៨ |
| គណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | ៦.៤៥៨.៥១៥ | ៦.៣៦១.៥៤៧ |
| | ១០៣.៨០៥.៣៥២ | ៧៨.៤៧៥.៨៧២ |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ (រយៈពេលខ្លី) | ១៩៩.៨១១.៤៤១ | ១៥៦.៥៩៩.៨០៥ |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ (រយៈពេលវែង និងរយៈពេលខ្លី) | ២៦៦.០៤៣.៣៣៦ | ២២១.៧៩៥.៦៤១ |

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ (ត)

### ១១. ចំណូលពីការលក់

| | មិនបានធ្វើសវនកម្ម សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី | |
|---|---|---|
| | ៣១ មីនា ២០២១<br>គិតជាពាន់រៀល | ៣១ មីនា ២០២០<br>គិតជាពាន់រៀល |
| ការលក់ទឹកស្អាត៖ | | |
| - អ្នកប្រើប្រាស់តាមផ្ទះ | ២៧.៩២៤.៦១៦ | ២៦.៨៧៧.០០៦ |
| - អ្នកប្រើប្រាស់ជាលក្ខណៈអាជីវកម្ម | ៣៣.៩៤៥.៣៨៧ | ៣២.១០៨.៧០៩ |
| - ស្ថាប័នរដ្ឋបាលសាធារណៈ | ៤.១០៣.៤៧៦ | ២.៨៤៨.៦០៩ |
| - អាជ្ញាធររដ្ឋស្វយ័តនានា | ១២០.៨៥១ | ១៤៤.២៥៨ |
| - អ្នកបោះដុំ | ២.២៥៦.២០៤ | ១.៩៥១.៤៧០ |
| បង្គត់ភាពខុសគ្នាលើប្រាក់ចំណូលពីការលក់ទឹកស្អាត | ១៦.២០១ | ១៥.៦៦៥ |
| ដកៈ ការលុបចោលវិក្កយបត្រ | (១.៧៥៤.០៧៩) | (៤៦៨.៨៣០) |
| | ៦៦.១១២.៦១៦ | ៦៣.៤៧៦.៨៨៧ |
| ចំណូលបានពីការភ្ជាប់បណ្តាញទឹកស្អាតតាមផ្ទះ | ១.៤៩៦.០៧១ | ២.៥៩១.៨៩៦ |
| ចំណូលការផ្លាស់ប្តូរនាឡិកាទឹក | ១.០៩៩.០៩១ | ៧៦៣.៥៥៦ |
| ការលក់គ្រឿងបន្លាស់ និងនាឡិកាទឹក | ២១.២៨៥ | ៥៥.៤៩៩ |
| | ៦៨.៧២៩.០៦៣ | ៦៦.៨៨៧.៨៣៨ |

### ១២. ចំណូលការប្រាក់

| | មិនបានធ្វើសវនកម្ម សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី | |
|---|---|---|
| | ៣១ មីនា ២០២១<br>គិតជាពាន់រៀល | ៣១ មីនា ២០២០<br>គិតជាពាន់រៀល |
| ចំណូលការប្រាក់ពីប្រាក់បញ្ញើនៅធនាគារ | ៤៦៣.៤៨៩ | ២៣២.១០៧ |
| ចំណូលមិនពិតពីការប្តូររូបិយប័ណ្ណ | ៧.៦៦៩.២៥៣ | ២.២៧៩.៣៤១ |
| | ៨.១៣២.៧៤២ | ២.៥១១.៤៤៨ |

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល
## សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ (ត)

## ១៣. ចំណាយការប្រាក់

| | មិនបានធ្វើសវនកម្ម សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី | |
|---|---|---|
| | ៣១ មីនា ២០២១ | ៣១ មីនា ២០២០ |
| | គិតជាពាន់រៀល | គិតជាពាន់រៀល |
| ចំណាយការប្រាក់លើប្រាក់កម្ចី | ១.៤៦៤.៧៨២ | ១.១១២.៩០០ |
| ខាតមិនពិតពីការប្តូររូបិយប័ណ្ណលើប្រាក់កម្ចី | - | ៤៦៧.២០៧ |
| ការប្រាក់ដែលបានធ្វើមូលធនកម្មលើទ្រព្យសកម្មមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ | (១.១៦៥.៩២៥) | (៧៦៤.៨០២) |
| | ២៩៨.៨៥៧ | ៨១៥.៣០៥ |

## ១៤. ពន្ធលើប្រាក់ចំណូល

ចំណាយពន្ធលើប្រាក់ចំណូលត្រូវបានទទួលស្គាល់ក្នុងទឹកប្រាក់ដែលបានគណនា ដោយយកប្រាក់ចំណេញមុនបង់ពន្ធសម្រាប់រយៈពេលរាយការណ៍ចន្លោះពេល គុណនឹងអត្រាពន្ធលើប្រាក់ចំណូលមធ្យមប្រចាំឆ្នាំដែលបានរំពឹងទុកសម្រាប់ពេញមួយឆ្នាំសារពើពន្ធ ដែលបានប៉ាន់ស្មានដ៏សមស្របបំផុតរបស់គណៈគ្រប់គ្រង ហើយធ្វើនិយ័តកម្មលើផលប៉ះពាល់ពន្ធលើឯកត្តាមួយចំនួនដែលបានទទួលស្គាល់ទាំងស្រុងក្នុងគ្រា។ ដូច្នោះ អត្រាពន្ធប្រសិទ្ធភាពនៅក្នុងព័ត៌មានហិរញ្ញវត្ថុចន្លោះពេលអាចខុសគ្នាពីការប៉ាន់ស្មានរបស់គណៈគ្រប់គ្រងលើអត្រាពន្ធប្រសិទ្ធភាពសម្រាប់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ។

អត្រាពន្ធប្រសិទ្ធភាពរបស់ រ.ទ.ស.ភ សម្រាប់ត្រីមាស និង រយៈពេល៣ខែគិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ គឺ ២៧% (សម្រាប់ត្រីមាស និងរយៈពេល៣ខែបញ្ចប់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ គឺ ២០%) ។ បម្រែបម្រួលអត្រាពន្ធប្រសិទ្ធភាព កើតឡើងជាចម្បងដោយសារការទទួលស្គាល់នៃបំណុលពន្ធពន្យាក្នុងត្រីមាស និងរយៈពេល៣ខែ បញ្ចប់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១។

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល
## សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ (ត)

### ១៥. ភាគលាភ

| | មិនបានធ្វើសវនកម្ម<br>សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី<br>៣១ មីនា ២០២១<br>គិតជាពាន់រៀល | <br><br>៣១ មីនា ២០២០<br>គិតជាពាន់រៀល |
|---|---|---|
| **ទទួលស្គាល់ក្នុងគ្រា** | | |
| ភាគលាភក្នុងការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ តម្លៃ២៦២រៀល ក្នុងមួយភាគហ៊ុនធម្មតា | ២២.៧៨៦.៩៦៥ | - |

### ១៦. ប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ

រ.ទ.ស.ភ មានប្រតិបត្តិការសំខាន់ៗជាមួយភាគីពាក់ព័ន្ធដូចខាងក្រោម៖

(ក) ស្ថាប័នរាជរដ្ឋាភិបាលពាក់ព័ន្ធ

សាជីវកម្មដែលភ្ជាប់ទៅនឹងរាជរដ្ឋាភិបាល គឺមានពាក់ព័ន្ធជាមួយ រ.ទ.ស.ភ ដែលត្រូវបានកាន់កាប់ភាគហ៊ុនដោយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ស្ថាប័នដែលគ្រប់គ្រងដោយផ្ទាល់ដោយរាជរដ្ឋាភិបាល ត្រូវបានសំដៅទាំងស្រុងជាស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធនឹង រ.ទ.ស.ភ។

រាជរដ្ឋាភិបាល និងស្ថាប័នដែលគ្រប់គ្រង ឬគ្រប់គ្រងរួមគ្នាដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា គឺជាភាគីពាក់ព័ន្ធជាមួយនឹង រ.ទ.ស.ភ។ រ.ទ.ស.ភ បានធ្វើប្រតិបត្តិការជាមួយស្ថាប័នជាច្រើន ដែលរួមមានមិនត្រឹមតែការទិញទំនិញប៉ុណ្ណោះទេ ថែមទាំងរួមមានការប្រើប្រាស់ទឹកជាសាធារណៈ និងការដាក់ប្រាក់បញ្ញើ។

រាល់ប្រតិបត្តិការទាំងអស់ដែលបានកត់ត្រាដោយ រ.ទ.ស.ភ ជាមួយស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ គឺត្រូវបានធ្វើឡើងក្នុងសកម្មភាពអាជីវកម្មធម្មតារបស់ រ.ទ.ស.ភ ស្តីពីលក្ខខ័ណ្ឌចរចារ ឬលក្ខខ័ណ្ឌប្រហាក់ប្រហែលនឹងស្ថាប័នផ្សេងទៀត ដែលមិនមែនជាស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ លើកលែងតែមានការបង្ហាញនៅកន្លែងផ្សេងទៀតនៅក្នុងព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

រ.ទ.ស.ភ បានពាក់ព័ន្ធយ៉ាងសំខាន់នៅក្នុងដំណើរការ និងការចែកចាយទឹកដែលជាផ្នែកមួយនៃប្រតិបត្តិការធម្មតារបស់ខ្លួន។ សេវាកម្មទាំងនេះត្រូវបានអនុវត្តជាប្រចាំ លើលក្ខខ័ណ្ឌពាណិជ្ជកម្មដែលត្រូវបានអនុវត្តជាមួយអតិថិជនទាំងអស់។ ប្រតិបត្តិការទាំងនេះត្រូវបានបង្កើតឡើងដោយផ្អែកលើលក្ខខ័ណ្ឌដែលមិនខុសគ្នាជាសារវន្តពីប្រតិបត្តិការជាមួយភាគីដែលមិនពាក់ព័ន្ធគ្នា។

ក្រៅពីប្រតិបត្តិការ និងសមតុល្យសំខាន់ៗជាមួយបុគ្គលនីមួយៗ ដូចបានបង្ហាញនៅកន្លែងផ្សេងទៀតនៅក្នុងព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល រ.ទ.ស.ភ មានប្រតិបត្តិការសំខាន់ៗជាសមូហភាព ប៉ុន្តែមិនមានប្រតិបត្តិការឯកបុគ្គលឡើយ។

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ (ត)

## ១៦. ប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ (ត)

(ខ) លាភការសម្រាប់គណៈគ្រប់គ្រងសំខាន់ៗ

លាភការសម្រាប់គណៈគ្រប់គ្រងសំខាន់ៗសរុបត្រូវបានវិភាគដូចខាងក្រោម៖

| | មិនបានធ្វើសវនកម្ម សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី | |
|---|---|---|
| | ៣១ មីនា ២០២១ | ៣១ មីនា ២០២០ |
| | គិតជាពាន់រៀល | គិតជាពាន់រៀល |
| ប្រាក់បៀវត្សរ៍ និងចំណាយផ្សេងៗ | ៥៦៦.៤២០ | ៦០១.២២៧ |

## ១៧. គោលដៅ និងគោលការណ៍នៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

គោលដៅនៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ គឺដើម្បីបង្កើនតម្លៃជាអតិប្បរមាសម្រាប់ភាគហ៊ុនិក ហើយទន្ទឹមគ្នានេះ ក៏កាត់បន្ថយសក្តានុពលជាអប្បបរមានៃផលប៉ះពាល់មិនល្អដែលអាចកើតឡើងដោយសារការប្រែប្រួលនៃទីផ្សារហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវលើការកំណត់គោលដៅទាំងនេះ និងគោលការណ៍មូលដ្ឋាននៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ។ ហេតុនេះ គណៈគ្រប់គ្រងបានបង្កើតគោលការណ៍លម្អិតដូចជា កម្រិតនៃសិទ្ធិអំណាច ការទទួលខុសត្រូវលើការត្រួតពិនិត្យ ការកំណត់ និងវាស់វែងអត្តសញ្ញាណហានិភ័យ និងកំណត់ផលប៉ះពាល់ដោយអនុលោមតាមគោលដៅ និងគោលការណ៍មូលដ្ឋានដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

(ក) ហានិភ័យឥណទាន

ហានិភ័យឥណទាន គឺជាការខាតបង់ផ្នែកហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ដោយសមភាគីមិនបានបំពេញកាតព្វកិច្ចដូចមានចែងក្នុងកិច្ចសន្យា។ រ.ទ.ស.ភ ប្រឈមនឹងហានិភ័យឥណទានភាគច្រើនពីការលក់ជាឥណទាន។ តាមគោលការណ៍របស់ រ.ទ.ស.ភ ត្រូវត្រួតពិនិត្យជាប្រចាំទៅលើស្ថានភាពហិរញ្ញវត្ថុរបស់សមភាគី ដើម្បីធានាថា រ.ទ.ស.ភ ប្រឈមនិងហានិភ័យឥណទានតិចបំផុត។

ហានិភ័យឥណទានដែល រ.ទ.ស.ភ ងាយរងផលប៉ះពាល់គឺ តាមរយៈគណនីអតិថិជនពាណិជ្ជកម្មដែលត្រូវទទួលពីអតិថិជន។ អាយុកាលឥណទានមានរយៈពេលមួយខែ ហើយ រ.ទ.ស.ភ ព្យាយាមធ្វើការគ្រប់គ្រងយ៉ាងដិតដល់លើគណនីត្រូវទទួលដែលមិនទាន់ប្រមូល ដើម្បីកាត់បន្ថយហានិភ័យឥណទានអោយបានទាបបំផុត។ សមតុល្យដែលហួសកំណត់ត្រូវបានត្រួតពិនិត្យឡើងវិញយ៉ាងទៀងទាត់ដោយគណៈគ្រប់គ្រង។

## រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល
## សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ (ត)

### ១៧. គម្រោងនៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ និងគោលការណ៍ (ត)

(ខ) ហានិភ័យសាច់ប្រាក់ងាយស្រួល និងហានិភ័យលំហូរសាច់ប្រាក់

ហានិភ័យសាច់ប្រាក់ងាយស្រួល និងហានិភ័យលំហូរសាច់ប្រាក់កើតឡើងពីការគ្រប់គ្រងរបស់ រ.ទ.ស.ភ ទៅលើមូលធនបង្វិល។ វាគឺជាហានិភ័យមួយដែល រ.ទ.ស.ភ នឹងជួបប្រទះផលលំបាកក្នុងការបំពេញនូវកាតព្វកិច្ចហិរញ្ញវត្ថុនៅពេលដែលដល់កាលកំណត់ត្រូវសង។

រ.ទ.ស.ភ គ្រប់គ្រងទិន្នន័យកាលវសាន្តរបស់បំណុល លំហូរសាច់ប្រាក់ពីប្រតិបត្តិការ និងភាពមានស្រាប់នៃមូលនិធិយ៉ាងសកម្ម ដើម្បីធានាបាននូវរាល់តម្រូវការប្រតិបត្តិការ ការវិនិយោគ និងហិរញ្ញប្បទាន។ នៅក្នុងយុទ្ធសាស្ត្រនៃការគ្រប់គ្រងហានិភ័យសាច់ប្រាក់ងាយស្រួល រ.ទ.ស.ភ ធ្វើការរក្សានូវកម្រិតសាច់ប្រាក់និងសាច់ប្រាក់សមមូល គ្រប់គ្រាន់សម្រាប់គាំទ្រដល់សកម្មភាពប្រតិបត្តិការរបស់ រ.ទ.ស.ភ។

(គ) ហានិភ័យអត្រាការប្រាក់

ហានិភ័យអត្រាការប្រាក់ គឺជាហានិភ័យដែលតម្លៃទីផ្សារ ឬលំហូរសាច់ប្រាក់នាពេលអនាគតនៃឧបករណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ អាចនឹងប្រែប្រួលដោយសារតែការប្រែប្រួលរបស់អត្រាការប្រាក់ទីផ្សារ។

ការប្រឈមរបស់ រ.ទ.ស.ភ ទៅនឹងហានិភ័យអត្រាការប្រាក់ ទាក់ទងនឹងកម្ចីជាចម្បង។ រ.ទ.ស.ភ គ្រប់គ្រងហានិភ័យអត្រាការប្រាក់របស់ខ្លួន ដោយត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់លើទីផ្សារបំណុល ហើយសំខាន់ជាងនេះទៀត គឺរក្សាអោយបានការលាយឡំគ្នារបស់អត្រាការប្រាក់ថេរ និងអត្រាការប្រាក់អថេររបស់កម្ចីដោយប្រុងប្រយ័ត្ន។ រ.ទ.ស.ភ ពុំបានប្រើប្រាស់ ដេរីវ៉េទីវឧបករណ៍ហិរញ្ញវត្ថុ ដើម្បីកាត់បន្ថយហានិភ័យរបស់ប្រាក់បំណុលដែលត្រូវសងនោះទេ។

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល
## សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ (ត)

## ១៨. ចំណាយជាប់កិច្ចសន្យា

នៅចុងត្រីមាសនៃការិយបរិច្ឆេទនេះ រ.ទ.ស.ភ បានជាប់កិច្ចសន្យាក្នុងការចំណាយមូលធនទៅលើទ្រព្យសកម្មដូចខាងក្រោម៖

| | មិនបានធ្វើសវនកម្ម<br>សម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី | |
|---|---|---|
| | ៣១ មីនា ២០២១<br>គិតជាពាន់រៀល | ៣១ មីនា ២០២០<br>គិតជាពាន់រៀល |
| ការសាងសង់រោងចក្រផលិតទឹកស្អាត | ៥២៨.៥១៥.៥៤៧ | ៤៥២.២៦១.២៦៩ |
| សេវាផ្តល់ការប្រឹក្សាយោបល់ | ១៤២.១៤៤ | ៦៨៨.៩១៩ |
| ការទិញបំពង់ដែកស្ទិត បរិក្ខារភ្ជាប់ និងបរិក្ខារផ្សេងៗ | ១៤១.០៦៨.២៦៨ | ១.០៥៦ |
| | ៦៦៩.៧២៥.៩៥៩ | ៤៥២.៩៥១.២៤៤ |

## ១៩. ព័ត៌មានតាមផ្នែក

ព័ត៌មានតាមផ្នែកមិនបានបង្ហាញ ដោយសារ រ.ទ.ស.ភ បានពាក់ព័ន្ធយ៉ាងសំខាន់នៅក្នុងដំណើរការ និងការចែកចាយទឹក សម្រាប់ប្រើប្រាស់ជាទូទៅ ដល់សាធារណជននៅក្នុងរាជធានីភ្នំពេញ និងការផ្តល់សេវាកម្មពាក់ព័ន្ធផ្សេងៗ ដែលស្ថិតនៅក្នុងផ្នែកអាជីវកម្មតែមួយ និងមានសង្គតិភាពស្របនឹងការអនុវត្តបច្ចុប្បន្ននៃរបាយការណ៍ផ្ទៃក្នុង។ រ.ទ.ស.ភ ធ្វើប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជា។

## ២០. ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល

ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុនសម្រាប់ត្រីមាស និងរយៈពេល៣ខែគិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០២១ ត្រូវបានអនុញ្ញាតឱ្យចេញផ្សាយស្របតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ ២០២១។

bakertilly

Baker Tilly (Cambodia) Co., Ltd.
Certified Public Accountants
No. 87, Street 294,
Sangkat Boeung Keng Kang 1,
Khan Chamka Morn,
Phnom Penh,
Cambodia

**T:** +855 23 987 100
**F:** +855 23 987 388

info@bakertilly.com.kh
**www.bakertilly.com.kh**

លេខបញ្ជីពាណិជ្ជកម្ម៖ Co.០៤៣៩ Et/២០១២

**របាយការណ៍ស្តីពីការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល**
**ជូនចំពោះសមាជិកនៃ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**សេចក្តីផ្តើម**

យើងខ្ញុំបានធ្វើការត្រួតពិនិត្យលើរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ហៅកាត់ថា "រ.ទ.ស.ភ" នាថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ព្រមទាំងរបាយការណ៍ប្រាក់ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល របាយការណ៍បម្រែបម្រួលមូលធនសង្ខេបចន្លោះពេល និងរបាយការណ៍លំហូរសាច់ប្រាក់សង្ខេបចន្លោះពេលសម្រាប់រយៈពេល៣ខែ និងកំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលដែលពាក់ព័ន្ធ (ត្រូវបានគេស្គាល់ថាជា "ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ រ.ទ.ស.ភ")។ ក្រុមប្រឹក្សាភិបាលរបស់ រ.ទ.ស.ភ ជាអ្នកទទួលខុសត្រូវក្នុងការរៀបចំ និងបង្ហាញភាពសមស្របនូវព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ រ.ទ.ស.ភ ដោយអនុលោមតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា លេខ ៣៤ ស្តីពី *របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល*។ ទំនួលខុសត្រូវរបស់យើងខ្ញុំ គឺធ្វើការសន្និដ្ឋានទៅលើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ រ.ទ.ស.ភ ដោយផ្អែកលើការត្រួតពិនិត្យឡើងវិញរបស់យើងខ្ញុំ។

**វិសាលភាពនៃការត្រួតពិនិត្យ**

យើងខ្ញុំបានធ្វើការត្រួតពិនិត្យ ដោយអនុលោមតាមស្តង់ដារអន្តរជាតិលើការត្រួតពិនិត្យ លេខ ២៤១០ ស្តីពី *ការត្រួតពិនិត្យព័ត៌មានហិរញ្ញវត្ថុចន្លោះពេលដែលធ្វើឡើងដោយសវនករឯករាជ្យរបស់ក្រុមហ៊ុន*។ ការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលរួមមាន ការចោទសួរបុគ្គលិកដែលពាក់ព័ន្ធផ្ទាល់នឹងព័ត៌មានហិរញ្ញវត្ថុ និងគណនេយ្យ ព្រមទាំងការអនុវត្តនូវការវិភាគ និងនិតិវិធីក្នុងការត្រួតពិនិត្យផ្សេងៗ។ ការត្រួតពិនិត្យមានវិសាលភាពតិចជាងការធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ហើយជាលទ្ធផល យើងខ្ញុំមិនអាចធ្វើការធានាថា យើងខ្ញុំបានដឹងនូវរាល់បញ្ហាសំខាន់ៗដែលអាចនឹងកំណត់បានប្រសិនបើធ្វើសវនកម្ម។ ដូច្នេះយើងខ្ញុំមិនអាចបញ្ចេញមតិយោបល់សវនកម្មនោះទេ។

AUDIT • TAX • ADVISORY

Baker Tilly (Cambodia) Co., Ltd. trading as Baker Tilly is a member of the global network of Baker Tilly International Ltd., the members of which are separate and independent legal entities.

bakertilly

លេខបញ្ជីពាណិជ្ជកម្មៈ Co.០៨៣៩ Et/២០១២

**របាយការណ៍ស្តីពីការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល**
**ជូនចំពោះសមាជិកនៃ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ក)**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**សេចក្តីសន្និដ្ឋាន**

យោងតាមការត្រួតពិនិត្យរបស់យើងខ្ញុំ មិនមានបញ្ហាណាមួយដែលធ្វើអោយយើងខ្ញុំជឿជាក់ថាព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ រ.ទ.ស.ភ ដែលបានភ្ជាប់មកជាមួយនេះមិនបានបង្ហាញនូវភាពសមស្រប គ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ មិនស្របទៅតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជាលេខ ៣៤ ស្តីពី *របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល* នោះទេ។

**បញ្ហាផ្សេងៗ**

របាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ សម្រាប់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ និងព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ រ.ទ.ស.ភ សម្រាប់ត្រីមាស និងរយៈពេល៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ត្រូវបានធ្វើសវនកម្ម និងពិនិត្យឡើងវិញដោយក្រុមហ៊ុនគណនេយ្យជំនាញ ដែលរបាយការណ៍ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១ និង ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ បានបង្ហាញនូវមតិសវនកម្មត្រឹមត្រូវ និងសេចក្តីសន្និដ្ឋានត្រឹមត្រូវ លើរបាយការណ៍ហិរញ្ញវត្ថុ និងព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលរៀងគ្នា។

**បេកឃើរ ធីលលី (ខេមបូឌា) ឯក.**
គណនេយ្យករជំនាញ

Tan Khee Meng
គណនេយ្យករជំនាញ

ថ្ងៃច័ន្ទ ៥កើត ខែប.សាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១

# ផ្នែកទី៤: ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

## ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

### ១- ការវិភាគចំណូល

រ.ទ.ស.ភ. មានចំណូល៣ប្រភេទធំៗគឺចំណូលបានមកពីការលក់ទឹកសេវាសាងសង់និងចំណូលផ្សេងៗ។

- ចំណូលបានមកពីការលក់ទឹករួមមាន: ចំណូលពីការប្រើប្រាស់ប្រភេទជីវភាពអាជីវកម្ម ឧស្សាហកម្ម អង្គភាពរដ្ឋ បន្ទប់ជួល និងអ្នកលក់ទឹកបន្ត។ ចំណូលទាំងនេះត្រូវបានរាយការណ៍តាមតម្លៃទទួលបានសុទ្ធ ក្រោយការកាត់កងជាមួយអប្បហារវិភាជន៍ និងឥណទានហើយត្រូវបានទទួលស្គាល់តាមបរិមាណទឹកដែលបានផ្គត់ផ្គង់ជូនអតិថិជនរបស់ខ្លួន។ ការធ្វើវិក្កយបត្រនៃការប្រើប្រាស់ទឹក ត្រូវបានធ្វើឡើងក្នុងរយៈពេលរៀងរាល់២ខែម្តង។

- ចំណូលបានពីសេវាកម្មសាងសង់: គឺជាចំណូលបានមកពីសេវាសាងសង់ ទាក់ទិនទៅនឹងការប្តូរ និងការពង្រីកប្រព័ន្ធចែកចាយទឹក ដែល រ.ទ.ស.ភ. បានសាងសង់ជូនក្រុមហ៊ុនសំណង់មួយ។

- ចំណូលផ្សេងៗរួមមាន: ចំណូលបានមកពីការថៃទាំនាឡិកាលក់សម្ភារ តបណ្តាញទឹក ការផាកពិន័យពីការប្រើប្រាស់ទឹកពុំមានការអនុញ្ញាតពី រ.ទ.ស.ភ. និងផ្សេងៗ។

  - **ចំណូលថែទាំនាឡិកា៖** គឺចំណូលបានពីថ្លៃឈ្នួលថែទាំនាឡិកាដោយគិតថ្លៃ៥០រៀលក្នុង១មីលីម៉ែត្រក្នុងមួយខែ នៃទំហំនាឡិកាទឹកក្នុងអំឡុងវដ្តនៃការគិតប្រាក់ ហើយត្រូវបានកត់ត្រាជាប្រាក់ចំណូល។ ចំណូលនេះ ត្រូវបានប្រើប្រាស់សម្រាប់ផ្លាស់ប្តូរនាឡិកាជូនអតិថិជននាពេលអនាគត។
  - **ចំណូលពីការលក់សម្ភារតបណ្តាញទឹក៖** គឺជាចំណូលទទួលបានពីការលក់នាឡិកាស្ទង់ទឹកបំពង់ និងសម្ភារតភ្ជាប់។
  - **ចំណូលពីការផាកពិន័យ៖** គឺជាចំណូលទទួលបានពីការផាកពិន័យលើការបង់ថ្លៃប្រើប្រាស់ទឹកយឺតយ៉ាវ និងពិន័យលើបទល្មើស តបណ្តាញទឹកដោយពុំមានការអនុញ្ញាតពី រ.ទ.ស.ភ.។
  - **ចំណូលផ្សេងៗ៖** គឺជាចំណូលទទួលបានមកពីការរួមចំណែករបស់អតិថិជនប្រភេទពាណិជ្ជកម្ម និងឧស្សាហកម្មក្នុងការវិនិយោគសម្រាប់ការភ្ជាប់បណ្តាញពិសេសចូលទីតាំងផ្ទាល់របស់ពួកគេ។ ក្រៅពីនោះ គឺជាចំណូលដែលទទួលបានពីកម្រៃសេវាលើការទារថ្លៃថែទាំលូទឹកស្អុយរបស់សាលារាជធានីភ្នំពេញ។

➤ **ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ប្រៀបធៀបជាមួយដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០**

| | ត្រីមាសទី១ ឆ្នាំ២០២១ (ពាន់រៀល) | ត្រីមាសទី១ ឆ្នាំ២០២០ (ពាន់រៀល) | បម្រែបម្រួល (ពាន់រៀល/ភាគរយ) | |
|---|---|---|---|---|
| ចំណូលសរុប | ៨៤.៣០៤.៧២៦ | ៧៥.៨១៧.៣១៦ | ៨.៤៨៧.៤១០ | ១១,១៩% |

រ.ទ.ស.ភ. មានចំណូលសរុប៨៤.៣០៤.៧២៦.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ និង៧៥.៨១៧.៣១៦.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ ដែលមានទឹកប្រាក់កើនឡើងចំនួន ៨.៤៨៧.៤១០.០០០រៀល ស្មើនឹង១១,១៩%។ យើងឃើញថាកត្តាចម្បងនៃការកើនឡើងនេះគឺ ដោយសារចំណូលពីការលក់ទឹកស្អាត បានកើនឡើងចំនួន ១.៨៤១.២២៥.០០០រៀល ស្មើនឹង២,៧៥% និងចំណូលពីសេវាកម្មសាងសង់ក៏មានការកើនឡើងប្រមាណ៣១៥,១៧% ស្មើនឹងទឹកប្រាក់ចំនួន ៥.២៨៩.៩២០.០០០រៀល។

### ២- ការវិភាគចំណូលតាមផ្នែក

ការវិភាគចំណូលតាមផ្នែករបស់រ.ទ.ស.ភ. មានដូចខាងក្រោម:

| | ត្រីមាសទី១ ឆ្នាំ២០២១ (ពាន់រៀល) | | ត្រីមាសទី១ ឆ្នាំ២០២០ (ពាន់រៀល) | |
|---|---|---|---|---|
| ចំណូលថ្លៃលក់ទឹក | ៦៨.៧២៩.០៦៣ | ៨១,៥២% | ៦៦.៨៨៧.៨៣៨ | ៨៨,២២% |
| ចំណូលពីសេវាកម្មសាងសង់ | ៦.៩៦៨.៣៤២ | ៨,២៧% | ១.៦៧៨.៤២២ | ២,២១% |
| ចំណូលពីការប្តូររូបិយប័ណ្ណ-សុទ្ធ | ៥៤៣.៦២៦ | ០,៦៤% | - | - |
| ចំណូលផ្សេងៗ | ៨.០៦៣.៦៩៥ | ៩,៥៦% | ៧.២៥១.០៥៦ | ៩,៥៦% |

# ក-ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ (ត)

## ២- ការវិភាគចំណូលតាមផ្នែក (ត)

មានតែប្រាក់ចំណូលតាមប្រភេទជាសារវន្តត្រូវបានលើកឡើងសម្រាប់ការវិភាគខាងក្រោម៖

➤ **ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ប្រៀបធៀបជាមួយដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០**

| | ត្រីមាសទី១ ឆ្នាំ២០២១ | | ត្រីមាសទី១ ឆ្នាំ២០២០ | | បម្រែបម្រួល | | |
|---|---|---|---|---|---|---|---|
| | បរិមាណ | ទឹកប្រាក់ | បរិមាណ | ទឹកប្រាក់ | បរិមាណ | ទឹកប្រាក់ | ទឹកប្រាក់ |
| | ម$^៣$/បណ | ពាន់រៀល | ម$^៣$/បណ | ពាន់រៀល | ម$^៣$/បណ | ពាន់រៀល | ភាគរយ |
| ការលក់ទឹកស្អាតជូនអ្នកប្រើប្រាស់តាមផ្ទះ | ២៧.៣០១.៩២០ | ២៧.៩២៤.៦១៦ | ២៦.១៩៩.៦៦១ | ២៦.៤០៨.១៧៦ | ១.១០២.២៥៩ | ១.៥១៦.៤៤០ | ៥,៧៤% |
| ការលក់ទឹកស្អាតជូនអ្នកប្រើប្រាស់ជាលក្ខណៈអាជីវកម្ម | ១៩.៣៦២.៥៣៩ | ៣៣.៤៤៥.៣៤៧ | ២០.៥២៩.៨៥៤ | ៣២.១២៤.៣៧៤ | (១.១៦៧.៣១៤) | ១.៣២០.៩៧៣ | ៤,១១% |
| ការលក់ទឹកស្អាតជូនគ្រឹះស្ថានសាធារណៈ | ១.៦៤១.៣៩០ | ៤.១០៣.៤៧៦ | ១.១៣៩.៤៤៤ | ២.៨៤៨.៦០៩ | ៥០១.៩៤៦ | ១.២៥៤.៨៦៧ | ៤៤,០៥% |

- **ចំណូលពីការលក់ទឹកស្អាតជូនអ្នកប្រើប្រាស់តាមផ្ទះ (ប្រភេទជីវភាព)**

រ.ទ.ស.ភ. មានចំណូលថ្លៃទឹកជីវភាពចំនួន២៧.៩២៤.៦១៦.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ និង ២៦.៤០៨.១៧៦.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ ដែលមានទឹកប្រាក់កើនឡើងចំនួន១.៥១៦.៤៤០.០០០រៀល ស្មើនឹង៥,៧៤%។ យើងឃើញថាការកើនឡើងនេះដោយសារចំនួនអតិថិជនបានកើនឡើងចំនួន ១១.៣៧០បណ្តាញ ពី ៣២៥.១១១បណ្តាញ ទៅ ៣៣៦.៤៨១បណ្តាញ។

- **ចំណូលពីការលក់ទឹកស្អាតជូនអ្នកប្រើប្រាស់ជាលក្ខណៈអាជីវកម្ម (ប្រភេទអាជីវកម្ម និងឧស្សាហកម្ម)**

រ.ទ.ស.ភ. មានចំណូលថ្លៃទឹកប្រភេទអាជីវកម្ម និងឧស្សាហកម្មចំនួន ៣៣.៤៤៥.៣៤៧.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ និង៣២.១២៤.៣៧៤.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ ដែលមានទឹកប្រាក់កើនឡើងចំនួន១.៣២០.៩៧៣.០០០រៀលស្មើនឹង៤,១១%។ យើងឃើញថាការកើនឡើងនេះដោយសារចំនួន អតិថិជនបានកើនឡើងចំនួន ៤.៨៩៧បណ្តាញ ពី ៦៤.០៣៩បណ្តាញ ទៅ ៦៨.៩៣៦បណ្តាញ។

- **ចំណូលពីការលក់ទឹកស្អាតជូនគ្រឹះស្ថានសាធារណៈ (ប្រភេទអង្គភាពរដ្ឋ)**

រ.ទ.ស.ភ. មានចំណូលថ្លៃទឹកប្រភេទអង្គភាពរដ្ឋ ចំនួន៤.១០៣.៤៧៦.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ និង២.៨៤៨.៦០៩.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ ដែលមានទឹកប្រាក់កើនឡើងចំនួន១.២៥៤.៨៦៧.០០០រៀល ស្មើនឹង៤៤,០៥% ដោយសារចំនួនអតិថិជនបានកើនឡើងចំនួន ៥១បណ្តាញ ពី ៧២៣បណ្តាញ ទៅ ៧៧៤បណ្តាញ។

## ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ (ត)

### ៣-ការវិភាគគម្លាតចំណេញដុល

រ.ទ.ស.ភ. បានរៀបចំរបាយការណ៍លទ្ធផលរបស់ខ្លួនក្នុងទម្រង់ជារបាយការណ៍លទ្ធផលតាមប្រភេទ ដូចនេះពុំមានការបង្ហាញឲ្យឃើញនៅចំណេញដុលនោះទេ។ ប៉ុន្តែក្នុងទម្រង់របាយការណ៍នេះអាចឲ្យយើងធ្វើការពិភាក្សា និងវិភាគលើចំណេញប្រតិបត្តិការ ដែលទទួលបានពីចំណូលសរុបដកនឹងចំណាយប្រតិបត្តិការ។

ចំណាយប្រត្តិបត្តិការនឹងលើកយកមកពិភាក្សានៅចំណុចទី ៤- ការវិភាគចំណេញ/(ខាត)មុនបង់ពន្ធខាងក្រោម។

### ៤- ការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ

ការចំណេញមុនបង់ពន្ធគឺជាលទ្ធផលដែលទទួលបានពីចំណូលសរុបដកនឹងចំណាយប្រតិបត្តិការ និងចំណូល/(ចំណាយ) ការប្រាក់សុទ្ធ។ ក្នុងការពិភាក្សា និងការវិភាគនៃចំណាយប្រតិបត្តិការ យើងលើកយកចំណាយរំលស់ទ្រព្យសកម្មរូបីអរូបីចំណាយលើការប្រើប្រាស់អគ្គិសនី និងចំណាយលើប្រាក់បៀវត្សរ៍ និងប្រាក់ឈ្នួលយកមកពិភាក្សា ដូចខាងក្រោម៖

➤ **ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ប្រៀបធៀបជាមួយដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០**

| | ត្រីមាសទី១ ឆ្នាំ២០២១ (ពាន់រៀល) | ត្រីមាសទី១ ឆ្នាំ២០២០ (ពាន់រៀល) | បម្រែបម្រួល (ពាន់រៀល/ភាគរយ) | |
|---|---|---|---|---|
| ចំណូលសរុប | ៨៤.៣០៤.៧២៦ | ៧៥.៨១៧.៣១៦ | ៨.៤៨៧.៤១០ | ១១,១៩% |
| ចំណាយរំលស់លើទ្រព្យសកម្មរូបី និងអរូបី | (១២.៦២០.៩៨៥) | (១២.៦៥០.១៧៤) | ២៩.១៨៩ | ០,២៣% |
| ចំណាយ ថ្លៃភ្លើង | (៨.៩៤៦.៧៩៤) | (៩.៧៣៨.៥៧២) | ៧៩១.៧៧៨ | ៨,១៣% |
| ចំណាយលើអត្ថប្រយោជន៍និយោជិក | (១៤.៦៨៥.៩៩២) | (១៣.៤១៧.៤៧៧) | (១.២៦៨.៥១៥) | (៩,៤៥%) |
| ចំណាយវត្ថុធាតុដើមសម្រាប់ផលិតទឹកស្អាត | (២.៩១២.៥៨៨) | (២.២៨៧.០០៨) | (៦២៥.៥៨០) | (២៧,៣៥%) |
| ចំណាយសេវាកម្មសាងសង់ | (៦.៥០៧.៣៥០) | (១.៥៦៨.៩៩៣) | (៤.៩៣៨.៣៥៧) | (៣១៤,៧៥%) |
| ចំណូលការប្រាក់ | ៨.១៣២.៧៤២ | ២.៥១១.៤៥៨ | ៥.៦២១.២៩៤ | ២២៣,៨៣% |
| ចំណាយការប្រាក់ | (២៩៨.៨៥៧) | (៨១៥.៣០៥) | ៥១៦.៤៤៨ | ៦៣,៣៤% |
| ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញ | ៤២.៤១៦.០៣៩ | ៣៣.១៥៦.៩១៣ | ៩.២៥៩.១២៦ | ២៧,៩៣% |

រ.ទ.ស.ភ. មានចំណេញមុនបង់ពន្ធលើប្រាក់ចំណេញចំនួន៤២.៤១៦.០៣៩.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ និង៣៣.១៥៦.៩១៣.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ ដែលមានទឹកប្រាក់កើនឡើងចំនួន ៩.២៥៩.១២៦.០០០រៀល ស្មើនឹង២៧,៩៣%។ យើងឃើញថាកត្តាចម្បងនៃការកើនឡើងនេះគឺ ដោយសារចំណូលសរុបបានកើនឡើងចំនួន៨.៤៨៧.៤១០.០០០រៀល ស្មើនឹង ១១,១៩% និងចំណូលការប្រាក់-សុទ្ធ ក៏បានកើនឡើងសម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ប្រមាណចំនួន ៦.១៣៧.៧៤២.០០០រៀល ស្មើនឹង៣៦១,៨៦% ទោះបីជាចំណាយសរុបបានកើនឡើងប្រមាណ១២,១០% ស្មើនឹងចំនួន ៥.៣៦៦.០២៦.០០០រៀល ក៏ដោយ។

## ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ (ត)

### ៥- ការវិភាគចំណេញ/(ខាត) និងលទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ

រ.ទ.ស.ភ. ស្ថិតក្រោមច្បាប់នៃក្រុមហ៊ុនពាណិជ្ជកម្មក្នុងវិស័យពន្ធដារ និងអាករ ដូចនេះរ.ទ.ស.ភ. មានកាតព្វកិច្ចត្រូវបង់ពន្ធ លើប្រាក់ចំណេញជាប់ពន្ធនូវអត្រា ២០%។ ដោយឡែកពន្ធលើប្រាក់ចំណេញដែល ជាប់អត្រា២០% បានមកពីលទ្ធផលនៃប្រាក់ចំណេញគណនេយ្យ ទូទាត់ជាមួយនឹងចំណាយដែលមិនអាចកាត់កងបានក្នុងអត្រាពន្ធ២០%។

➢ **ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ប្រៀបធៀបជាមួយដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០**

| | ត្រីមាសទី១ ឆ្នាំ២០២១ (ពាន់រៀល) | ត្រីមាសទី១ ឆ្នាំ២០២០ (ពាន់រៀល) | បម្រែបម្រួល (ពាន់រៀល/ភាគរយ) | |
|---|---|---|---|---|
| ចំណេញមុនបង់ពន្ធ (ក) | ៤២.៤១៦.០៣៩ | ៣៣.១៥៦.៩១៣ | ៩.២៥៩.១២៦ | ២៧,៩៣% |
| ចំណាយពន្ធលើប្រាក់ចំណេញ (ខ) | (១១.៦៤៤.៤៣០) | (៦.៥៥២.៩៦៩) | (៥.០៩១.៤៦១) | (៧៧,៧០%) |
| ចំណេញក្នុងការិយបរិច្ឆេទ | ៣០.៧៧១.៦០៩ | ២៦.៦០៣.៩៤៤ | ៤.១៦៧.៦៦៥ | ១៥,៦៧% |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | ៣០.៧៧១.៦០៩ | ២៦.៦០៣.៩៤៤ | ៤.១៦៧.៦៦៥ | ១៥,៦៧% |
| អត្រាពន្ធប្រសិទ្ធភាពលើប្រាក់ចំណេញ (ខ)/(ក) | ២៧,៤៥% | ១៩,៧៦% | | |

រ.ទ.ស.ភ. មានចំណេញក្នុងការិយបរិច្ឆេទចំនួន ៣០.៧៧១.៦០៩.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ និង២៦.៦០៣.៩៤៤.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ ដែលមានទឹកប្រាក់កើនឡើងចំនួន៤.១៦៧.៦៦៥.០០០រៀល ស្មើនឹង១៥,៦៧%។ ការកើនឡើងនេះដោយសារ ចំណេញមុនបង់ពន្ធបានកើនឡើងចំនួន ៩.២៥៩.១២៦.០០០រៀល ស្មើនឹង២៧,៩៣%។

### ៦-ការវិភាគពីកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

ផលចំណេញដែលទទួលបានកន្លងមក ក៏ដូចជាកំណើនពីមួយឆ្នាំទៅមួយឆ្នាំ គឺដោយសារតែមានកត្តាគាំទ្រ ដូចខាងក្រោម៖

- **អត្រាទឹកបាត់បង់៖** រ.ទ.ស.ភ. បានប្រើប្រាស់នូវយន្តការដ៏មានប្រសិទ្ធភាព ដើម្បីកាត់បន្ថយអត្រាទឹកបាត់បង់មកត្រឹម១១,៥១% ប៉ុណ្ណោះនៅត្រីមាសទី១ ឆ្នាំ២០២១នេះ។ កត្តានេះជាកត្តាចម្បងដែលធ្វើឲ្យ រ.ទ.ស.ភ. មានចេរភាពហិរញ្ញវត្ថុ និងអភិវឌ្ឍសហគ្រាស រក្សានូវស្ថានភាពហិរញ្ញវត្ថុ និងការអភិវឌ្ឍសហគ្រាសប្រកបដោយនិរន្តភាព។

- **ការបង្កើនចំនួនអតិថិជន៖** ដើម្បីទទួលបាននូវចំណូលពីការលក់ទឹកស្អាត រ.ទ.ស.ភ. បានបង្កើនចំនួនអតិថិជនរបស់ខ្លួន ដោយពង្រីកផ្ទៃសេវាផ្គត់ផ្គង់ទឹកស្អាតទៅតំបន់ដែលពុំទាន់មានការផ្គត់ផ្គង់ទឹកស្អាត ដូចជាការបំពេញផ្ទៃសេវាឲ្យបាន ១០០% នៅក្នុងរាជធានីភ្នំពេញ តំបន់ជុំវិញរាជធានីភ្នំពេញ ជាពិសេសតំបន់ដែលមានសក្តានុពលសេដ្ឋកិច្ច។

- **ការបង្កើនថ្លៃលក់ទឹកមធ្យម៖** តាមរយៈការស្វែងរកអតិថិជន ដែលជាប្រភេទអាជីវកម្ម-ឧស្សាហកម្ម ធ្វើឲ្យថ្លៃលក់ទឹកមធ្យមរបស់ រ.ទ.ស.ភ. កើនឡើងដោយសារតែថ្លៃប្រើប្រាស់ទឹករបស់អតិថិជនប្រភេទនេះមានកម្រិតខ្ពស់ជាងអតិថិជនប្រភេទផ្សេងទៀត។

- **ការគ្រប់គ្រងលើការចំណាយប្រតិបត្តិការ៖** រ.ទ.ស.ភ. ធ្វើការគ្រប់គ្រងលើការចំណាយនេះ ពិសេសការចំណាយលើការប្រើប្រាស់ថាមពលអគ្គិសនីដែលជាចំណាយដ៏ធំ និងសំខាន់ក្នុងដំណើរការប្រព្រឹត្តកម្មទឹកស្អាត តាមរយៈការប្រើប្រាស់នូវបច្ចេកវិទ្យាថ្មីៗ ដូចជាជ្រើសរើសយកការប្រើប្រាស់ម៉ាស៊ីនបូមទឹកដែលអាចប្រែប្រួលទៅតាមសម្ពាធទឹក។ នៅឆ្នាំ២០១២ រ.ទ.ស.ភ. ចាប់ផ្តើមប្រើប្រាស់វត្ថុធាតុដើមក្នុងការធ្វើប្រព្រឹត្តកម្មទឹកដែលមានប្រសិទ្ធភាពខ្ពស់ គឺមានតម្លៃទាប ដូចជាការប្រើប្រាស់សារធាតុបណ្តុំកករ(PAC) ជំនួសសាច់ជូរ។

- **ការអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវដំណើរការកិច្ចលទ្ធកម្ម៖** រ.ទ.ស.ភ. បានអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវច្បាប់បញ្ញត្តិ និងគោលការណ៍ ណែនាំផ្សេងៗសម្រាប់ដំណើរការកិច្ចលទ្ធកម្មក្នុងការទិញបំពង់ សម្ភារ និងវត្ថុធាតុដើម ដែលដំណើរការនេះឆ្លុះ

បញ្ជាំងឲ្យឃើញពីតម្លាភាព និងការប្រកួតប្រជែងថ្លៃទំនិញនៅលើទីផ្សារ ដែលជាហេតុធ្វើឲ្យ រ.ទ.ស.ភ. ទទួលបានការទិញនូវតម្លៃទាបតែក៏មិនមើលរំលងនូវគុណភាពនោះដែរ។

- **ការគ្រប់គ្រងសាច់ប្រាក់៖** តាមរយៈអត្រាទារប្រាក់ដែលមានកម្រិតខ្ពស់ខាងលើនេះធ្វើឲ្យ រ.ទ.ស.ភ. មានលទ្ធភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងសាច់ប្រាក់ដោយទទួលបាននូវប្រសិទ្ធភាពខ្ពស់។ ក្នុងការគ្រប់គ្រងនេះ រ.ទ.ស.ភ. បានរក្សាទុកនូវសាច់ប្រាក់សម្រាប់ប្រើប្រាស់ជាទុនបង្វិលក្នុងរយៈពេល ២ទៅ៣ខែ ឯសាច់ប្រាក់ដែលទំនេរនោះ រ.ទ.ស.ភ. បានធ្វើការវិនិយោគរយៈពេលខ្លី ដោយដាក់ប្រាក់បញ្ញើមានកាលកំណត់រយៈពេលខ្លីនៅធនាគារពាណិជ្ជ ជាមួយនឹងការទទួលបាននូវអត្រាការប្រាក់ខ្ពស់តែ រ.ទ.ស.ភ. ក៏បានធ្វើការថ្លឹងថ្លែងពីហានិភ័យ និងផលចំណេញពីអត្រាការប្រាក់ខ្ពស់នេះដែរ។

- **ការជ្រើសរើសយកនូវអ្នកផ្តល់ហិរញ្ញប្បទានដែលផ្តល់អត្រាការប្រាក់ទាប៖** ដោយសារមានតម្រូវការប្រើប្រាស់ទឹកស្អាតកើនឡើងខ្ពស់ ធ្វើឲ្យ រ.ទ.ស.ភ. មានតម្រូវការហិរញ្ញប្បទានសម្រាប់គម្រោងវិនិយោគដូចជាការសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាត ការតបណ្តាញមេនាំទឹក និងបណ្តាញចែកចាយ។ រ.ទ.ស.ភ. បានស្វែងរកដៃគូអភិវឌ្ឍអន្តរជាតិដូចជាទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍(AFD) ដើម្បីទទួលបាននូវហិរញ្ញប្បទាន ដែលមានអត្រាការប្រាក់ទាប។

- **ស្ថានភាពសេដ្ឋកិច្ច៖** ការប្រែប្រួលនូវស្ថានភាពសេដ្ឋកិច្ចជះឥទ្ធិពលលើមធ្យមភាគនៃការប្រើប្រាស់ក្នុងមួយបណ្តាញក្នុងមួយខែ ដែលធ្វើឲ្យមានការប្រែប្រួលទៅលើកម្រិតនៃថ្លៃលក់ទឹកមធ្យម។

## ខ- កត្តាសំខាន់ដែលប៉ះពាល់លើប្រាក់ចំណេញ

### ១- ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

ដោយយោងទៅតាមការសិក្សានៃតម្រូវការប្រើប្រាស់ទឹកធៀបទៅនឹងកំណើនប្រជាជន នៅក្នុងរាជធានីភ្នំពេញ ដោយសារការពង្រីកតំបន់ជុំវិញរាជធានីភ្នំពេញ រ.ទ.ស.ភ. បានធ្វើការសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតចំការមនថ្មី ដែលមានសមត្ថភាពផលិត៥២.០០០ម៣/ថ្ងៃ និងត្រូវធ្វើការសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតសម្រាប់គម្រោងផ្គត់ផ្គង់ទឹកស្អាតបាក់ខែងដំណាក់១ ដែលមានសមត្ថភាពផលិត ១៩៥.០០០ម៣/ថ្ងៃ ដើម្បីបំពេញតម្រូវការទឹកស្អាតនាពេលអនាគត។

### ២- ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម

ការប្រែប្រួលនៃថ្លៃវត្ថុធាតុដើមសម្រាប់ប្រព្រឹត្តកម្មទឹកស្អាត អាចប៉ះពាល់ដល់ថ្លៃដើមផលិត ប៉ុន្តែមិនមានផលប៉ះពាល់ធ្ងន់ធ្ងរនោះទេ ដោយសារការចំណាយនេះមានអត្រាមិនលើសពី១០% នៃចំណាយប្រតិបត្តិការ។ ទោះជាយ៉ាងណាក៏ដោយ រ.ទ.ស.ភ. ក៏បានអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវនីតិវិធីលទ្ធកម្ម ដើម្បីធានាថ្លៃវត្ថុធាតុដើមសមស្របទៅតាមតម្លៃលើទីផ្សារជាក់ស្តែង ហើយនីតិវិធីនេះក៏ផ្តល់លទ្ធភាពសម្រាប់ រ.ទ.ស.ភ. ទទួលបាននូវតម្លៃប្រកួតប្រជែងដែលមានតម្លៃទាប។

### ៣- ការវិភាគលើពន្ធ

រ.ទ.ស.ភ. ស្ថិតក្រោមច្បាប់នៃក្រុមហ៊ុនពាណិជ្ជកម្មក្នុងវិស័យពន្ធដារ និងអាករ ដូចនេះរ.ទ.ស.ភ. មានកាតព្វកិច្ច ត្រូវបង់ពន្ធ អាករ ទៅតាមច្បាប់ និងបញ្ញត្តិជាធរមាន។ រ.ទ.ស.ភ. មានកាតព្វកិច្ចបង់ពន្ធអាករ ទៅតាមរបបពិត និងជាសហគ្រាសជាប់ពន្ធធំ ដែលកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ។

### ៤- ការវិភាគលើធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ

នាដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ខែធ្នូ ឆ្នាំ២០២០នេះ គណៈគ្រប់គ្រងយល់ថា រ.ទ.ស.ភ. ពុំមានធាតុដែលខុសពីធម្មតា និងវិសាមញ្ញនោះទេ។

## គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ចំណូលសំខាន់របស់ រ.ទ.ស.ភ. គឺការលក់ទឹកស្អាត ដែលជាតម្រូវការចាំបាច់របស់ប្រជាជននៅក្នុងរាជធានីភ្នំពេញ។ ចំណូល ពីការលក់ទឹកស្អាតនេះ បានចូលរួមចំណែកលើសពី៨០% នៃចំណូលសរុបនៅត្រីមាសទី១ ឆ្នាំ២០២១នេះ ហើយ រ.ទ.ស.ភ. ក៏ជាអ្នក ផ្គត់ផ្គង់ផ្តាច់មុខនៅក្នុងរាជធានីភ្នំពេញ និងតំបន់ជុំវិញរាជធានីភ្នំពេញ។ ប្រាក់ចំណូលអាចមានការកើនឡើង អាស្រ័យទៅតាមចំនួនប្រជាពលរដ្ឋដូចជាការពង្រីករាជធានីភ្នំពេញ និងការធ្វើចំណាកស្រុករបស់ប្រជាជននៅតាមបណ្តាខេត្តមករស់នៅក្នុងរាជធានីភ្នំពេញ។

## ឃ-ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

### ឃ.១- ផលប៉ះពាល់នៃអត្រាប្តូរប្រាក់

រ.ទ.ស.ភ. បានកត់ត្រាបញ្ជីគណនេយ្យដោយប្រើប្រាស់រូបិយប័ណ្ណគោលគឺ "ប្រាក់រៀល"។ ប្រតិបត្តិការជារូបិយ-ប័ណ្ណបរទេសត្រូវបានប្តូរទៅជារូបិយប័ណ្ណគោលតាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញ និងខាតដែលបណ្តាល មកពីការទូទាត់ប្រតិបត្តិការបែបនេះការប្តូរទ្រព្យសកម្ម និងបំណុលរូបិយប័ណ្ណបរទេសត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផលលម្អិត។

### ឃ.២- ផលប៉ះពាល់នៃអត្រាការប្រាក់

#### ឃ.២.១- ផលប៉ះពាល់នៃអត្រាការប្រាក់លើចំណូលការប្រាក់

ដោយសារនៅប្រទេសកម្ពុជាពុំមានទីផ្សាររូបិយប័ណ្ណ ដូច្នេះ រ.ទ.ស.ភ. មានលទ្ធភាពត្រឹមតែវិនិយោគរយៈពេលខ្លីលើការដាក់ប្រាក់បញ្ញើមានកាលកំណត់រយៈពេល១ឆ្នាំ នៅធនាគារពាណិជ្ជក្នុងស្រុកតែប៉ុណ្ណោះ។

#### ឃ.២.២- ផលប៉ះពាល់នៃអត្រាការប្រាក់លើចំណាយការប្រាក់

រ.ទ.ស.ភ. មានប្រភពហិរញ្ញប្បទានពីរ ដែលមានអត្រាការប្រាក់ថេរ និងប្រែប្រួល។ ហិរញ្ញប្បទានដែលមានអត្រាការប្រាក់ថេរ មានហិរញ្ញប្បទានដែលទទួលតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) នៅអត្រា១,៦៥% និងភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន(JICA) នៅអត្រា០,៦៦%ក្នុងមួយឆ្នាំ។

ហិរញ្ញប្បទានដែលមានអត្រាការប្រាក់ប្រែប្រួលមាន ហិរញ្ញប្បទានពីទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍(AFD) នៅអត្រា EURIBOR ៦ខែ ដក១,៣៥ពិន្ទុ។ តែអត្រានេះមិនឲ្យទាបជាង០,២៥% និងមិនខ្ពស់ជាង៥,២១% ក្នុងឆ្នាំនោះទេ។

#### ឃ.២.៣- ផលប៉ះពាល់នៃថ្លៃទំនិញ

តាមរយៈដំណើរការកិច្ចលទ្ធកម្មរបស់ រ.ទ.ស.ភ. ដែលអនុលោមទៅតាមច្បាប់ និងបញ្ញត្តិជាធរមាន រួមផ្សំនឹងគោលការណ៍ណែនាំផ្សេងៗ ដែលតម្រូវឲ្យ រ.ទ.ស.ភ. ធ្វើកិច្ចសន្យាជាមួយអ្នកផ្គត់ផ្គង់សម្ភារ និងវត្ថុធាតុដើមទៅតាមតម្លៃប្រកួតប្រជែង ឬតម្លៃថោករបរួច។ ទោះបីជាមានបម្រែបម្រួលនៃបរិមាណប្រើប្រាស់វត្ថុធាតុដើមក៏ដោយ វត្ថុធាតុសម្រាប់ការប្រព្រឹត្តកម្មទឹកមានចំណែកតូច បើប្រៀបធៀបនឹងការចំណាយដំណើរការនៅឆ្នាំនីមួយៗ។ គណៈគ្រប់គ្រងជឿជាក់ថាបម្រែបម្រួលនៃបរិមាណប្រើប្រាស់នេះមិនប៉ះពាល់ធ្ងន់ធ្ងរដល់ស្ថានភាពហិរញ្ញវត្ថុរបស់សហគ្រាសឡើយ។

## ង- ផលប៉ះពាល់នៃអតិផរណា

រ.ទ.ស.ភ. បានរក្សានូវថ្លៃលក់ទឹកថេរមិនប្រែប្រួលចាប់តាំងពីឆ្នាំ២០០១ រហូតដល់ឆ្នាំ២០១៩។ ដើម្បីធ្វើការកែសម្រួលទៅតាមការប្រែប្រួលនៃអតិផរណា យើងបានធ្វើការកែសម្រួលនូវថ្លៃលក់ទឹកស្អាតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ ដល់បច្ចុប្បន្ន ហើយនៅតែរក្សាបាននូវចេរភាពហិរញ្ញវត្ថុបានយ៉ាងល្អប្រសើរ។

## ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រដ្ឋាភិបាល

ធុរកិច្ចរបស់ រ.ទ.ស.ភ ទទួលការជះឥទ្ធិពលពីគោលនយោបាយមួយចំនួន ដែលកំណត់ដោយរាជរដ្ឋាភិបាលដូចជា៖

- **ការពង្រីកផ្ទៃសេវា៖** ការពង្រីកផ្ទៃសេវាបន្ថែមដើម្បីផ្គត់ផ្គង់ទឹកស្អាត ត្រូវបានរឹតត្បិតដោយបេសកកម្មរបស់ រ.ទ.ស.ភ. ដែលអនុញ្ញាតឲ្យផលិត និងចែកចាយទឹកសម្រាប់ការប្រើប្រាស់របស់សាធារណជននៅក្នុងរាជធានីភ្នំពេញតែប៉ុណ្ណោះ ការរឹតត្បិតនេះត្រូវបានកំណត់ដោយអនុក្រឹត្យលេខ ៥២អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៦ ស្តីពីការបង្កើត រ.ទ.ស.ភ.។
- **ការពង្រីករាជធានីភ្នំពេញ៖** រាជរដ្ឋាភិបាលមានគោលនយោបាយពង្រីករាជធានីភ្នំពេញ ដោយបញ្ចូលឃុំ បន្ថែមទៀត ទៅក្នុងតំបន់រាជធានីភ្នំពេញដែលធ្វើឲ្យផ្ទៃសេវារបស់ រ.ទ.ស.ភ. ក្នុងការផ្គត់ផ្គង់ទឹកស្អាតក៏ត្រូវពង្រីកបន្ថែមដែរ។
- **គោលនយោបាយពន្ធលើអចលនទ្រព្យ៖** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានដាក់ឲ្យអនុវត្តនូវប្រកាសលេខ ៤៩៣សហវ.ប្រក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ ស្តីពី " ការប្រមូលពន្ធលើអចលនទ្រព្យ" ។ អចលនទ្រព្យរបស់ រ.ទ.ស.ភ. គឺសម្រាប់បម្រើឲ្យប្រព័ន្ធផលិតកម្មទឹកស្អាត ដែលអចលនទ្រព្យប្រភេទនេះ ត្រូវបានលើក-លែងពន្ធ តាមរយៈសេចក្តីជូនដំណឹងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ០០០៦សហវ.អពដ. ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១។

# ផ្នែកទី ៥.- ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន

ក្នុងត្រីមាសទី១ ឆ្នាំ២០២១ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ពុំមានព័ត៌មានចាំបាច់ផ្សេងទៀតត្រូវបង្ហាញទេ។

# ហត្ថលេខាអភិបាល
# របស់ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

ថ្ងៃច័ន្ទ ៥កើត ខែប.សាឍ ឆ្នាំឆ្លូវ
ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១
បានអាន និងឯកភាព

ហត្ថលេខា
**អ៊ុំ សុថា**
ប្រធានក្រុមប្រឹក្សាភិបាល

ថ្ងៃច័ន្ទ ៥កើត ខែប.សាឍ ឆ្នាំឆ្លូវ
ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១
បានអាន និងឯកភាព

ហត្ថលេខា
**ស៊ឹម ស៊ីថា**
អភិបាល

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ.)**

: +៨៥៥(២៣) ៧២៤ ០៤៦

: ir@ppwsa.com.kh

: WWW.PPWSA.COM.KH

អគារលេខ ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ